- ព្រះភរុណាព្រះបាទសម្តេចព្រះ **ឆនរោត្តម**

- - ដ - ព្រះបាទសម្តេចព្រះ **សុីសុវត្ថិ**

- - ដ - ព្រះបាទសម្តេចព្រះ **មុនិវង្ស**

- - ដ - ព្រះបាទសម្តេចព្រះ**ឆនរោត្តម សីហនុវរ័ន**

- - ដ - ព្រះបាទសម្តេចព្រះ**ឆនរោត្តម សុរាម្រិត**

កំណត់បំណាំ

សូមបំណាំអក្ខរាវិរុទ្ធនៃពាក្យដូចតទៅ ៖

- **ព្រះមហាក្សត្រ** = ក្សត្រ *អាចសរសេរ* ក្សត្រ ឬ ក្សត្រិយ៍ ។

- **ឯីមួយ** ។ = *កុំសរសេរ* ឯីមួយ ។ *ដូចេ្នះ* ។

- **សន្ធតិ** = *អាចសរសេរ* សម្ពន្ធ *ដូចេ្នះហាន* ។

មិនត្រូវសរសេរ សន្ធតិ *ដូចេ្នះទេ* ។

- **ឥាចារ** = *គ្មានន័យដូចេ្នះទេ* ។

- **ប្រព្រឹត្ត** = *ជាកិរិយាសព្ទ* ។ *បើជានាមត្រូវសរ.*

សេរ ប្រព្រឹត្តិ ប្រែថាការធ្វើតាម (ឧ. ការប្រព្រឹត្តិ, សេចក្តីប្រព្រឹត្តិ) ។

សូមចំណាំ ព្រ ដាក់ស្រៈ ឹ មិនមែន ស្រៈ ឺ ទេ ។

- **សាធារណៈ** = ណា ខាងបុរមានយុគលពីន្ទុ(:)

- **ស្មើ** = គ្មាន រ ខាងបុរទេ ។

- **ឫកពារ** = កុំសរសេរ រ៉ឹកពា ។

ពា គ្មាន រ ខាងបុរទេ ។

កុំប្រឡំនឹងពាក្យ ឫកពារ ប្រែថាវៃឆ្លាត (ឧ. ចេញត្រូវឫកពារពេលជាបវរ កើត ល្អ កុំខក ប្រើនវ៉ៃក្រែពេកពាន់) ។

- **ឧទ្ទេសពិធ(១)** = សរសេរស្ទើគ្មានដើម-ចុង ទេ ។

---

(១) ឧទ្ទេសពិធរាជធម៌ មាន: ១- ទាន: = ការឲ្យទាន ។ ២- សីល:

ពិធ សរសរស្រ: = និងធ្វ ។

- អាសវ= ឥតទ្រង់ធ្មប់ដេ ។

កុំប្រមូនឹង អ្នសារ ប្រែថា ឥតខ្វីម,

ឥតប្រយោជន៍ ។

- ស្វាមីតភ្ជិ = កុំប្រមូ ភ័ក្ត្រ ម្ដ ភ័ក្ត្រ (សេចក្តីពន់-

ពាន) ន ភ្ជាក្រ ម្ដ ភ្ជាក្រ (មុខ) ។

= ការរក្សាសីល ៥ ជានិច្ច។ ๓- បវិច្ចាគ = ការចំណាយព្រះរាជទ្រព្យ

ទំនុកបំរុងព្រះនគរ ។ ๔- អាជ្ញ: = មានសេចក្តីត្រង់ ។ ๕- មជ្ជវ:

= មានសេចក្តីទន់ភ្លន់ ស្លូត សុភាពរាបសា ។ ๖- តប: = ការកាន់ខ្នោ

សថសីលតាមកាលកំណត់ម្តងៗ ។ ๗- អក្កោធន: = មិនកំណើរក្រហាយ

អ្នកដទៃ ។ ๘- អវិហឹសា = មិនបៀតបៀនអ្នកដទៃ ។ ๙- ខន្តិ = មាន

សេចក្តីអត់ធន់ ។ ๑๐- អវិរោធន: = មិនបំពានលើធម៌ លើប្បាប់ ។

ទី ៣.- ដំណើរជួជកជួបនិងចេតបុត្រ(១)

ភ្យុំណោះ ចេតបុត្រថ្មើរព្រៃកំពុងត្រាច់រង្គាត់ទៅក្នុងព្រៃ ឮជូជកស្រែកទ្រហោយំរកព្រះបាទស្រីវេស្សន្តរបរាពោធិសត្វដូច្នេះកូរ ចេតបុត្រក៏ស្រែកគំរាមទៅថា ម្នុយព្រាហ្មណ៍កញ្ជាស់ ម្ចេចក៏មកយំសោករកព្រះអង្គ ប៉ើដោយអញ្ជើរំពឹងគិតទៅឃើញថាព្រាហ្មណ៍កញ្ជាស់នេះឯងមករកសុំទាន ទើបវាំងត្រាច់មកដល់អាស្រមសុំអ្នកមាលប្បាយ តាំងពីព្រះអង្គគង់នៅក្នុងព្រះភូមិវាំង ដរាបមកគង់នៅក្នុងកំគីរីវង្កត រាំនាំគ្នាសុំទាំងដំរីបច្ចយនាគន្ត្រូជាព្រះរាជទំនងដ៏ប្រសើរ ពួករាស្ត្រសព្វសុំគ្រប់ តុំគិតប្រណីដោយក្តីតណ្ហាលោភលន់ ទាល់តែអ្នកនគរខិធជាគោលាហល នាំគ្នាក្រាបបង្គំទូលប្តឹងផ្តល់សម្ចេចព្រះវ

---

(១) ចាប់ពីអត្ថបទទី ៣ គឺជាអត្ថបទដែលចេញហើយក្នុងការប្រទ្បងមធ្យមសិក្សាបឋម ឆ្នាំទី ៧ ។ ខ្ញុំមិនធ្វើការឆ្លើយសំនួរទេ ពីព្រោះកុំឲ្យប្រុំដែលនឹងសៀវភៅឯទៀតហើយដើម្បីឲ្យបានចំនួនអត្ថបទប្រើនសំរាប់សិស្សានុសិស្ស យកទៅអានពិបាកណា ។ នៅខាងក្រុងនីមួយៗ ខ្ញុំគ្រាន់តែធ្វើកំណត់សំគាល់ខ្លះផ្នែកអក្ខរាវិរុទ្ធ។

បិតាឲ្យស្នេចបំបរបង់ព្រះអង្គចេញចាកព្រះនគរ ព្រះអង្គតាង
នាំព្រះពរជបុត្រាបុត្រីនិងព្រះពរជទេវី មកគង់ក្នុងកំគីរវង្កត ។
ព្រោហ្មណ៍តញ្ចាសនេះឯងហើយ ជាមនុស្សអបលក្ខណ៍
ខំដើរស្វែងមកគេព្រះពរជបុត្រាបុត្រី ដូចកូនបក្សី គឺកុក
រនាល តាលឯណាបានយល់ត្រីក្នុងបឹងត្រពាំង ក្នុងរដូវប្រាំង
រីងទឹកហែងហួតហើយ តែងហើរមកគេចាប់បឹកធំជាបល្ងុះតែ
អស់ ។
ព្រោហ្មណ៍អប្រិយនេះឯងជាមនុស្សអន្ធពាល កំណាច
អាចតាមបំផ្លាញព្រះអង្គជាប្រាកដ ឥតមានបេះគេធីបុគលគ់
ខន្ធិញ ។
ព្រោហ្មណ៍ចង្រៃអើយ កុំខន្ធឹងគេព្រះអង្គទៀយ អញ
ពុំខ្លុកជីវិតព្រះស្នេងឲ្យស៊ីនៅតទៅទៀតទេ អញបាញ់ទឹងធ្វើ
ឲ្យត្រូវដើមទ្រូង រួងយកថ្មីមប្រមាត់ញ៉ាំភ្លា បូជាក្រួងពាលីធ្វើ
ពលីការទេពតាគគ្រាប្រកក្នុង ឯកប្បាលព្រះស្នេងសោត អញនឹង
ដោតថ្វាយអ្នកតានៅព្រៃក្នុងនេះ ។

សំដួរ

១- ចូរពន្យល់ពាក្យ : ថ្នើរដីធ, មាលប្រាយ, នាគន្ត្រូ, អបលក្ខណា, អន្ទពាល, ពលការ ។

២- ចូរអ្នកសង្ខិប្ត្រប្រែយោគ : "ឯកប្បាលប្រស្នែង សោត អញ្ញទីធ៌ជោតថ្ងាយអ្នកតានៅនាព្រៃភ្នំនេះ" ។

៣. ចូរអ្នកស្រង់ខ្លួន ពាក្យពហុព្យាង្គ ដែលមានព្យាង្គតម្រែត ហើយបញ្ជាក់អំពីរបៀបតម្រែតព្យាង្គ ។

មធ្យមសិក្សាបត្រ លើកទី ១ ថ្ងៃទី ៨-៦.៥៩

កំណត់ចំណាំ

១- អក្ខរាទិវុទ្ធ.-

- ជួជក (អានថា ជួដក់) សរសេរគ្មានបន្ទក់លើ ក ទេ ។ គឺជាឈ្មោះព្រាហ្មណ៍ម្នាក់ ជាសម្ភូកធ៌រឿងវេស្សន្តរជាតក ។

- កិរិណា (មកពី សំស្ក្រឹត កិរ្ណា, ចាលីថា ខិណា)

- សរសៃនឹង ក្រ ស្រះ ៖ និង ណា ។

- កំពូល (ជានិបាតសព្ទ) ។ កុំប្រទូន្មឹង កំពង់ (ជានាម, គឺមាត់ទឹក) ។ កំពង (ជា គុណនាម, ប្រៃថា ពេញកំពូក) ។

- ក្រាច់ (ប្រភេទឆ័ត្រសរសេរ ក្រែប) ។ ដូចជ្រុះកុំសរសេរ ក្រែប (សុំអាន ន.ន.ឯ. ភាគ ១ ឬ ទំព័រ ៣៧១) ។

- ក្រហោយំ (ក្រហា គ្មាន រ ប្រសំខេ) ។

- ព្រះរាជទាំង (រឹង អាចសរសេរ រឹង ដូចជ្រុះបាន) (ន.ន.ឯ. ភាគ ២ ទំព័រ ១១៩០)

- ជរាយ (ជ គ្មានអស្ថា (ំ) ពីរលើខេ) — កុំប្រទូន្មឹង ជ (និបាត) ។

- ភ្នំគិរីទត្តគ (ជានាម, សរសេរ រ៉ាង្គ គ គ្មាន បន្ថែរលើ ពីរ ខេ ។ ជារឈ្មោះភ្នំមួយក្នុង

ពួកកំហឹមពាន្ត) ។

- **ជីនជ័ន** អាចសរសេរ ជីវ៉ាំង ដូច្នេះបាន (គឺជី អង្គុយ, ប្តីសម្រាប់ឥស្ត្រីយ៍ទ្រង់ប្រថាប់) ។

- **ជ្រីងជ្រល់** (ប្រឹង សរសេរនឹង ប ។ ធ្លុល់ សរសេរនឹង ធ ។ តែគេអាចសរសេរ ប្រឹងប្រល់ ឬ ប្រឹងប្រល់ ក៏បានដែរ) (សុំអាន វ. ន. ។. ភាគ ๑ ទំព័រ ๖๓๘) ។

- **អបលក្ខណ៍** ប្តីសរសេរ: អប៉លក្ខណ៍ ក៏បាន ។

๒- **សទិសសព្ទ** : នៃពាក្យ

๑- ពោធិសត្ត :

- **ពោធិសត្ត** = (នាម) អ្នកដែលសំពុងខំប្រឹងប្រែងបំពេញបារមី បម្រងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ។

- **ពោធិសាត់** = (នាម) គេអានថា ពោ-សាត់ ជាឈ្មោះខែត្រមួយនៃភូមិភាគឧដុងមីង ។

២- ជីង :

- **ជីង** = (កិរិយានុគ្រោះ) ស្មែកខ្ញុំ ជីង ទៅផ្សារ ។
(ត្រាប់អនាគតកាល = le futur) ។

- **ជីង** = (គុ. ឬ កិរិយាវិសេស) អង្គុយ ជីង ក្តក់, ដំធឹទៅ ជីង, ទឹក ជីង ។

- **ជីង** = (អាយតនិបាត) កាន់ ជីង ដៃ, ភ្ជាប់ ជីង ដញ្ជាំង, ទៅ ជីង ខ្ញុំ, ដេកស៊ី ជីង គេ ។
(ត្រូវនឹងពាក្យបារាំងថា avec, au) ។

- **ជីង** = (អាយតនិបាត) ជា អកថិតកម្ម ។ ឧ. ពីមុំលែមញ្ញ គេបាននិយាយនូវពាក្យនេះ ជីង ខ្ញុំថា . . .

- **ជីង** = (និបាត) ត្រូវនឹងពាក្យបារាំងថា et, អ្នក ជីង ខ្ញុំ, គោ ជីង ក្របី, សុខ ជីង ទុក្ខ ។

៣- លក្ខណ៍ :

- **លក្ខណា** ឬ **លក្ខ្យណា** = (នាម) លក្ខណៈ (ឧ.

មនុស្សខាត លក្ខណ៍) (អាចសរសេរបាន
ជា ល័ក្ខណ៍ ឬ លក្ខ្មណ៍) ។

- **លក្ខ ឬ លខ** = (នាម) ដរខ៖រង (ខ. លក្ខ ដុ
ក្រឡ) ។

- **លក្ខ្មណ៏ ឬ លក្ខ្មណ:** = (នាម) នាមព្រះ
អនុជរបស់ព្រះរាម (ខ. ព្រះរាមនិងព្រះ
លក្ខ្មណ៍) ។

៤- កល :

- **កល** = (នាម) ល្បិច, ឧបាយយ៉ាងល្អិត (ខ-
ឧបាយ កល) ។

- **កល់** = (កិ.) ទ្រពីក្រោម (ខ. ដាក់កំណល់ កល់
ពីក្រោម) ។

x

x x

ទី ៤.- រឿងចចកនិងស្គរ

មានចចកមួយស្រែកឃ្លានខ្លាំង ដើរស្វែងរកអាហារ ត្រមង់ត្រមោច កាត់ព្រៃ រក្សា លតាវល្មិ គីរីបពិត បាននឹញ្ញ ស្មាមសមរកូមិចាស់មួយ ដែលកងទ័ពចង្រាំងតតាំងគ្នា ។ សេនាគហានដែលចង្រាំងគ្នា ហើយដើរបាត់ទៅ បាននាំស្គរមួយទើរនៅលើមែកឈើ ។ មែកឈើនោះ កាលបើមានខ្យល់បក់មក ក៏ហាក់ដូចជាទៅវាយស្គរនោះឮសូរខ្លាំង ។ ចចកឮហើយ កំតក់យតក្តុមាញ៉ាវន្ទត់សឮសពាំងគ្គកាយ គិតថា " ខ្ញុំអន្ទពយដល់ហើយ បើនៅឆ្ងាយទៅព៌នឹងគេច ចេញទ្បាផុត តែណ្ហើយចុះ អាត្មាអញមិនគួរប្រញាប់ប្រញាល់ លះបង់ព្រៃ ជាទីហានដ៏មានៅរមជីដូនដីតាទេ ព្រោះថា កងទ័ គ្រាមានអាសន្ន ប្តូមានសេចក្តីកពយមកដល់ ទស្សនវិស័យ ឆ្លើកឡើងអ្វីៗ ដោយរហ័សពេក គេពិចារណា គេមិនក្តៅ-ក្រហាយ កើតមានវិប្បដិសារីទ្បើយ ។ បើដូចនេះ អាត្មាអញ ត្រូវចូលទៅមើលទ្បាបក្ខពន្ធឹងក្លែក នូវសំឡេងនេះសិន " ។

ចចកសំដែងសេចក្តីក្លាហានយ៉ាងម៉ឺងម៉ាត់ ដើរតម្រង់
ទៅដិត ឃើញស្មុកញ្ជាស់មួយទើរនៅលើមែកឈើ ពិនិត្យ
ឃើញយ៉ាងប្រត្យក្សថា កាលណាមានខ្យល់បក់មក មែក
ឈើដែលរយាលទៅមក ទៅប៉ះនឹងស្មុរ ហាក់ដូចជាគេវាយ
ឮស្មុរខ្លួនឯង ។ កាលណាឥតខ្យល់ ក៏ឮស្មុរទៅ ។

ចចកយល់ច្បាស់ជាស្មុរហើយ ក៏ដើរចូលទៅដិតយក
ដៃវាយលើងដោយក្តីបំណងយ៉ាងម៉ឺងម៉ាត់ ហើយគិតថា
“ខ្ទុស្មុរនេះ ឃ្លានជាគោជនាហារប្រាថ្នាណាស់ ពីយូរយារ
ណាស់មកហើយ អាត្មាអញពុំដែលមានភ័ព្វវាសនា ឃ្លានអា
ហារប្រាថ្នាម៉្លេះទេ ខាងក្នុងប្រហែលជាពោរពេញទៅដោយ
សាច់ និងខ្លាញ់ប្រាថ្នាអនេកប្បការហើយ” ។

ខណៈនោះ ចចកក៏ខំប្រឹងតែរហោះទម្លុះស្បែកពាស
ស្មុរចេញក្រៅមកក្រោះឆ្អែលចូលទៅខាងក្នុង ដោយចិត្តសោម-
នស្សក្រៃលែង ដល់ហើយគ្មានឃើញអ្វី តើតក្តីអាក់អន់ចិត្ត

គោលដៅពាក្យស្នើគឺថា : " ខ្ញុំ ឬ ដួចស្នា ខាងក្រោម.

ហោងឆ្នង " ។

សន្ធរ

១. ចូរពន្យល់ពាក្យ សមរភូមិ, វិប្បដិសារី, រុក្ខា, លតា, បច្ចក្ខ, ប្រត្យក្ស, អនេកប្បការ ។

២- ចូរធ្វើសង្ខេបពាក្យ ក្នុងប្រយោគ " បើដួច នេះ អាត្មាអញត្រូវប្រុលទៅមេលទ្បាបច្ចក្ខនឹង ភ្នែក ខ្លួវសំឡងនេះសិន " ។

៣- ចូរកត់សម្គាល់ នឹងពាក្យ " ការ " ហើយចង់ជាប្រយោគ ។

៤- រឿងនេះ មានគតិយ៉ាងណា ?

មធ្យមសិក្សាច័ត្រ

លើកទី ២ ថ្ងៃ ១-៨-៥៨

កំណត់ចំណាំ

១. **អក្ខរាវិរុទ្ធ** ៖-

- **ឥណ្ឌិ** សរសេរ ឥ - ណ្ឌិ (អានថា រ័ល) ។
- **ឧធីរ** មានន័យថាចុង ។
- **មណ្ឌារម** (រម សរសេរ ន ធ ម ។ កុំច្រឡំ ន ធ រម្យ ទម ដែលអាចសរសេរជា រម ទម ក៏បាន) ។
- **ឋីដូនឋីតា** (មិនមែន ជី ដូន ជី តាទេ) ។
- **អាសន្ន** សរសេរ អា-ស ន ធ ន្ន ។
- **រហ័ស** អាចសរសេរក្លាយជា រហស់ ក៏បាន (អាន វ.ន.ឃ. ភាគ ២ ទំព័រ ៨៧៤) ។
- **សំឡេង** មិនសរសេរ ស ម្ដែង ដូច្នេះទេ ។ (អាន វ.ន.ឃ. ភាគ ២ ទំព័រ ១៤១៥) ។
- **តម្រង់** សរសេរតម្រួត មកពីពាក្យ ត្រង់ ។ ពីមុន សរសេរ តំរង់ ឬ ដំរង់ ឬ ដម្រង់ ដូច្នេះបាន ។

- **ពិនិត្យ** សរសេរ ពិ-ធិ នឹង ត្យ ។

- **ប្រែក្ស** អាចសរសេរជា ប្រែក្សា ឬ ប្រែក្សោ ។

បង្កូ ឬ បង្កួ ។
๑ ๒

- **ស្ទែះ** មិនមែនសរសេរ ម្ទែះ ដូច្នេះទេ ។
๙

២- **សទិសសព្ទ** នៃពាក្យ :

១- ឆៅ.-

- **ឆោង** ជាកិ. ប្រែថា បិត, ស្ថិត, មាន (នៅឯណា ? នៅផ្ទះ) ។

- **ឆោង** ជាកិ.វិសេស ប្រែថា ដែលមិនខាន់, ដែលមានទៀត (អស់ហើយឬនៅ ? នៅ !) ។

- **ឆួង** ជា និបាត ប្រែថា និង, ហើយនិង (ព្រះរាជ-វង្សានុវង្ស និងមន្ត្រីងតូច នូវអស់ប្រជាជនទាំងពួង) ។

- **ឆួង** ជា អា.និ. គឺពាក្យប្រាប់ដំណើរសម្រេចអំពីដែលគេត្រូវធ្វើ (ប៉ុគ្គលធ្វើនូវអំពើល្អ ដោយ

កាយ វាចា ចិត្ត ទឹងបានន្ទូវផលល្អ) ។

២- ណែ:.—

— **ឯង:** ស. គំពាក្យសម្រាបបង្ហាញ ចង្អុលអ្វី ដែលនៅឆ្ងាយ តែប្រាកដ (សំបុត្រនោះ, អ្នកនោះ) ។

— **ឯ:** សព្វ. គំពាក្យសម្រាប់និយាយចង្អុលប្រាប់ន្ទូវ អ្វី ។ មើលទៅយើញ ប៉ែនមិនឆាយពេកទេ (បន្ទាត់អ្នកណានុ:) ។

— **ឯ:** សព្វ. ប្រែថា ហ្នឹង គំពាក្យសម្រាប់និយាយ ចង្អុលនាមសព្វ ដែលនៅឃ្លាតឆ្ងាយប្រើនពីខ្លួន តែមើលទៅយើញ (អ្នកណានុ:!? នុ:ន ! ។

៣- ក៏.—

— **ក** ជានាម គឺអវយវ:ដែលតពីក្បាលទៅស្មា (កដៃ- កជើង — កមនុស្ស) ។

- **ក** ជាកិ. ប្រែថាតាំងផ្តើម តាំងឆ្ងើ (កសាង; កកើត, កកួមិ) ។

- **កី** ជា នំ. សម្រាប់និយាយតប្រយោគ (អ្នកកំសៅ, ខ្ញុំកំសៅ)

សូមចំណាំ

- **កកាន** (កការប្រែឆ, បិត្តុកការស្អុត)

- **កកួន** (សម្ដ កកួរ)

- **កកេរកាន** (កគេរពោត)

x

x x

ទី៥- បុណ្យភ្ជុំបិណ្ឌ

បុណ្យភ្ជុំបិណ្ឌ ជាបុណ្យដែលខ្មែរទាំងប្រទេសបានរង្វើ គ្រប់គ្នាឥតមានខាន ដើម្បីឧទ្ទិសរំលែកដល់ឫទ្ធិបុរសនឯញាត សាលោហិតដែលបាននៅកាន់បរលោក ។ បុណ្យនេះ ធ្វើបានតែដប់ថ្ងៃគត់ គឺថ្ងៃមួយរោចខែកត្តិក ទៅទល់នឹងថ្ងៃដាច់ខែ ។

ខ្ញុំព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលជាសាសនារបស់រដ្ឋ មានសាមគ្គីធម៌ជាមួយគ្នា ដោយសំណេរសាលកថាពិធីភ្ជុំបិណ្ឌនេះ ។

នៅគ្រប់តែវត្តអារាមក្នុងព្រះពុទ្ធចក្រ ខ្ញុំបាទ ខ្ញុំបាទិកា ព្រមទាំងខ្ញុំទាសជាប់បម្រើគ្រប់ប្រភេទ ទាំងខ្ញុំទាសជាប់បម្រើបុគ្គលទាំងឡាយរបស់ខ្លួនទេ ថែមទាំងខ្ញុំទាសជាប់ជួងវិញ្ញាណនៃខមរកូមិន្ទនិងខមរ-ជនអ្នកស្នេហាជន អ្នកស្នេហាជាតិទាំងឡាយ ដែលបានទទួលមរណភាពនាសមរភូមិក្នុងតំការបំរើមាតុប្រទេស និងខ្ញុំទាសជាប់វិញ្ញាណក្ខន្ធនៃអ្នកនិពន្ធនិងកវីនានា ដែលបានបំរើអក្សរសាស្ត្រនិងវប្បធម៌ជាតិ ឲ្យមានកន្លែងដំណែលរុងរឿងស្ថិតស្ថេរជាកេរ្តិ៍ភាព ។

គំនរបុណ្យដែលកើតឡើងអំពីអាមិសទាន និងធម្មទាន ក្នុងបុណ្យភ្ជុំបិណ្ឌនេះ ពលរដ្ឋខ្មែរទាំងមូលបានខ្ញុំទាសថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រិយានី

សូមព្រះអង្គទ្រង់ស្ថិតជាបរមសុខឈ្នះអស់មារសត្រូវ ហើយ
សូមកុសលទាំងនោះ ជំរុញទាំងតែជាតិខ្លួន ឲ្យរឹតតែស្រឡាញ់
ជាតិជាយស្វាមីភក្តី ។

ជាពិសេស សូមឥដ្ឋមនុញ្ញផលនេះដួយគ្រាន ដួយកម្ចាត់
អំពើបំផ្លាញជាតិឲ្យវិនាសសាបសូន្យ ហើយសូមឲ្យសាមគ្គី
ធម៌តទីរឹងប៉ឹងជាបរិបូណ៌ ហាក់ជាខ្សែរវេញជាដួងមួយ ។

សំណួរ

១- ចូរពន្យល់ពាក្យ បុព្វ, ភរិ, កិរិយាភាព
អាមិសទាន, ឥដ្ឋមនុញ្ញផល ។

២- ចូរសង្ខេបពាក្យក្នុងឃ្លា "ឧត្តមកិច្ចនេះ
ពលរដ្ឋខ្មែរបានប្រកាន់យក តាំងពីបុរាណ
រៀងមក" ។

៣- ពាក្យបរិបូណ៌ គេអាចសរសេរបានប៉ុន្មាន
យ៉ាង? ចូរពន្យល់ហើយបញ្ជាក់ដោយឧទាហរណ៍ជាឃ្លាផង។

៤- អ្វីខ្លះដែលជាអន្តរាយ នៃព្រហ្មវិហារតាមព្រះពុទ្ធសាសនា ?

មធ្យមសិក្សាបឋម
លើកទី១ ថ្ងៃ៤៨-៣-៦០

បម្លើយ(១)

១- ពន្យល់ពាក្យ·-

- **ឫទ្ធ** ជាគុ. ប្រែថាមុន, ខាងដើម, ពីមុន (ឧ.ឫទ្ធ-កថា, ឫទ្ធកម្ម, ឫទ្ធណ្ហសមយ, ឫទ្ធនមត្ត, ឫទ្ធនិវាស, ឫទ្ធនជាតិ, ឫទ្ធបទ, ឫទ្ធបយោគ ឬ ឫទ្ធប្បយោគ, ឫទ្ធបុរស, ឫទ្ធសន្ធិ, ឫទ្ធ-ហេតុ . . .) ។

- **កតី** ជានាម (មកពីសំ.ឃ.ថា កឹ) គឺអ្នកប្រាជ្ញដែលចេះតែងនូ កាព្យឃ្លោង ឬអ្នកប្រាជ្ញខាងសំដី ។

---

(១) បំពោះអត្ថបទនេះ ខ្ញុំធ្វើបម្លើយតែ៣ទេ ដើម្បីទុកជាឯកសារជូន។

កុំថា អ្នកកវី ។ ល។ ថា អ្នកនិពន្ធ និងកវី ។

- **តិរយ្យាគារ** ជានាម (មកពីបា. តិរយ្យា + គារ) ប្រែថា ដំណើរប្រែនក្រៃលែង, គារៈលើសលែង ។ គេប្រើជាគុ. កិ៍បាន (មានៈអំណាចជាតិរយ្យាគារ) ។

- **អាមិសធារណ** ជានាម (មកពី បា. អាមិស + ធានៈ) អាមិស ប្រែថាសាច់ (ដែលប្រើជាអាហារ) - ធានជាបច្ចុប្បន្ន គឺ បីវៈ (គ្រឿងស្លៀកដណ្តប់), បិណ្ឌបាត (អាហារ), សេនាសនៈ (លំនៅ) និងគិលានភេសជ្ជៈ (ថ្នាំរំងាប់ជំងឺ, រំងាប់ពេគ) ។

- **ផលូទកញ្ញាណ** ជានាម (មកពី បា. ផល + ឧទកញ្ញាណ) ប្រែថាផលជាទីពេញចិត្ត ដែលបានសម្រេចដូចបំណង ។

២- ពាក្យ បវរិបូណ៌ .-

គេអាចសរសេរបាន ៣ យ៉ាង :

- **បវរបូរ** ជាគុ. (ម្ហូបនេះបវរបូរណាស)
- **បវរិបូណ៌** ជាគុ. ឬ កិ. (ស្រែកបវរិបូណ៌, ព្រះមហាសថមានបញ្ញាបវរិបូណ៌អស្ចារ្យ, ព្រះពោធិសត្វបវរិបូណ៌ទៅដោយបញ្ញា) ។
- **បវរបូរណា** ជានាម (អ្នកបវរបូរណាដោយបញ្ញារមែងតែឈ្នះឧបសគ្គនានា) ។

៣_ អង្គនៃព្រហ្មវិហារ តាមព្រះពុទ្ធសាសនា .-

ព្រហ្មវិហារ ជានាម ប្រែថា ធម៌ជាទីនៅនៃព្រហ្ម ធម៌ជាលំនៅនៃចិត្តដ៏ប្រសើរ មាន ៤ យ៉ាងគឺ :

១ - **មេត្តា** ផ្សាយសេចក្តីពាប់អានៅកសព្វសត្វ ។

២ - **ករុណា** ផ្សាយសេចក្តីអាណិតនៅកសព្វសត្វ ។

៣- ម្ចុងតា ផ្សាយអំណរៅកសព្វសត្វ ដែល
បានសេចក្តីចម្រើន គឺមានអំណាចធំគេបាន
ស្មុខ ចម្រើន ។

៤- ឧបេក្ខា ផ្សាយសេចក្តីស្មោះស្មើរៅកសព្វសត្វ។

កំណត់ចំណាំ

១- អក្ខរាទិវុទ្ធ .-

- រំលឹក អាចសរសេរ រំឭក ក៏បាន ។
- ស្និទ្ធស្នាល (ស៊ិន្ធ សរសេរ ស្និ ន ធ ទ្ធ) ។
- អាណាចក្រ អាចសរសេរ អាណាបក្ក ក៏បាន។
- ឧបាសក ឧបាសិកា (សក សរសេរផង បន្តក់ខេ ។ សិក្ខា គ្មានរ៉ ខាងចុងខេ) ។
- ឧដ្ឋិស សរសេរ ទឹងស្រៈឹ ។
- ទាំងឡាយ អាចសរសេរ ទាំងបា្លយ ដូចខ្លះ ក៏បាន ។

(អានវិន.វ. ភាគ ១ ទំព័រ ៤៦១) ។

– **តូមិដ្ឋ** (ម៉ិ ជ្ជ សរសេរ ម៉ិ ន៓ ជ្ជ) ។

– **បម្រៀ** (ក្នុង ន.ន.ខ. ភាគ ប្ដី ទំព័រ ៥៥៥) មិនសរសេរ បំរែ ដូច្នេះទេ គឺមកពីពាក្យ ប្រែ ទៅជា បម្រែ គឺសរសេរតម្រួតដូចគ្នា ។ បម្រែ បម្រៃស់ (បម្រៃស់ មកពីពាក្យ ប្រាស់)។

– **ស្មកស្ដង្គ** (ស្ម សរសេរ ស្ម ន៓ ង្គ) ។

– **តិរេយ្យាតាព** (មិនសរសេរ ភៃយ្យោភាព ដូច្នេះទេ) ។

– **គំនរ** (សរសេរ ជ ន៓ រ ។ ដូចជា គរ ទៅជា គំនរ) ។

– **ព្រះមហាក្សត្រិយានី** (អាន ក្សត្រិយ៉ានី តែសរសេរជា ក្សត្រិយានី ដូច្នេះ) ។

– **ស្ដិត** អាចសរសេរជា ប្ដិត ដូច្នេះបាន ។

– **ទឹត** (សរសេរ ទ្ធ៓ ន៓ ត) ។

– **កម្ចាត់** (អាន ន.ន.ខ. ភាគ ១ ប្ដី ទំព័រ ២៣) មិនសរ-

សេរ កំបាត់ដូច្នេះទេ ។ កម្ចាត់ មកពីពាក្យ ចាត់ ។ គឺត្រូវសេរសេរ តម្រួតដូចគ្នា) ។

២- សទ្ធិសស្ទ នៃពាក្យ :

១- សព្ទ : .-

- **សព្ទ** ជា គុ. ឬ កិ.វិ. ប្រែថា ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់, គ្រប់, ទូទៅ, ពាល់ (ឃើញសព្ទ, ឮសព្ទ) ។

- **សព្ទ** ជា កិ. មានន័យថា ពេញ, តាប់, ស្មុគ្រ ស្មោះ, ត្រូវ, ឥតខ្ចុះ, ឥតខាស់ (សព្ទ-ព្រះទ័យ) ។

- **សព្ទ** ជា វិ.ស, ឬ គុ. ប្រែថា ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់, គ្រប់, គ្រប់យ៉ាង, ទូទៅ, ពាល់ (សព្ទគុណ = គុណ-សម្បត្តិគ្រប់យ៉ាង ។ សព្ទញាតញាណ, សព្ទញាតិ, សព្ទញាតិ, សព្ទញ្ញូ, សព្ទយុត្ត, សព្ទលោក,

សព្វវចនៈ, សព្វវិទូ ។ល។ . . .) ។

- **សព** ជា នាម ប្រែថា ខ្មោចស្រស់, រូបបុគ្គល ស្លាប់, សាកខ្មោច (តំកល់សព, ធ្វើបុណ្យ សព) ។

- **សម** ជា គុ. ស្មើបរាជ័យស្មើប (សមទឹក, សម-គង់ឡាន) ។

๒- រ បើ.-

- **រថ** ជា នាម ប្រែថា រាជធីមាសេះ (រថសេះ, ពលរថ, រថយន្ត) ។

- **រតំ** ជា គុ. ប្រែថា ស្ទុះដោយលឿន (រត់ខ្លឹត) ។

๓- រ ជ្ជ.-

- **រជ្ជ** ជា នាម ប្រែថា ដែន, ប្រទេស (រដ្ឋធម្មនញ្ញ, រដ្ឋជានី) ។

- **រតែ ន ឬ រត្តែ** (រតេន ឬ រត្ត) ជា នាម ប្រែថា កែវ,

ពេជ្រ, ត្បូងគ្រប់ប្រភេទ (ព្រះរតនត្រ័យ, ពុទ្ធ-
រតន: ឬ ពុទ្ធរត្ន៍) ។

៤- ជីវ.-

- ជន ជានាម ប្រែថា សព្វសត្វដែលកើតក្នុងលោក
មនុស្ស, អ្នកផង (បណ្តាជន) ។

- ជន់ ជាកិ. ប្រែថា ខ្សែឆកាយកាយ (ទឹកជន់)។

៥- មារ.-

- មារ ជានាម ប្រែថា ដំណើរពពាំង, ការសម្លាប់,
សេចក្តីស្លាប់, អ្នកពពាំង, ឈ្មោះទេវបុត្រ
ដែលជាសត្រូវចំពោះព្រះពុទ្ធ (មារជ្រៃក) ។

- មារ ជានាម (ដុំពុកមា) ។

៦- រឹត.-

- រឹត ជាកិ. ធ្វើឲ្យតឹង (រឹតខ្សែ) ; បំរើនឲ្យឆ, ខ្ទាំង
ឲ្យឆ (ដំណឹរឹត, រឹតដៃ) ។

– **វីត** ជានាម (ស្លឹកវត) ។

– **វីត** វតៃត ជាន. កាន់តែ, ជេះតែ, (វតខូច, វត
តែខ្លាំងខ្លៅ) ។

– **វីតត្សិត** ជាគុ. ប្រៃតប្រៀប, ប្រៃតខ្លាំង ។

– **វីជ្ជិ ឬ ឫជ្ជិ** ជានាម ប្រែថា សេចក្តីសម្រេច, អំណាច, សេចក្តីអស្ចារ្យ, រុងរឿង (ប្រឡងឫជ្ជិ, ប្រើឫជ្ជិអំណាច) ។

x

x x

ទី ๖– ជីវិតសាបសូន្យក្នុងអាថ៌កំបាំងលើនាវា

ព្រះទិនតវនេវ៉ាប្រែះមាត់ព្រៃ ពុំមានអស្ចឹតនោះឡើយ
នេ ។ អរុណរង្សីនៅភ្លឺច្រាល ចាំងមកលើព្រះពជជានី ជាតីអាសាន ។ មេឃស្រឡះថ្លាយដ៏រកពពកមួយដុំគ្មាន ស្រមោលធម្មជាតិឆ្នេះបូលទៅកណ្តាលគង្គា ឃើញវែងអន្លាយ ហើយខ្លៅសូន្យ ។ ។

ក្រឡាះហាមគង់ អង្គុយនៅត្រមោចឯកឯង លើនាវ
មានទឹកមុខក្រៀមក្រំជាពន្លឹក ខំប្រឹងសំឡឹងមើលនៅត្រើយ
ខាងលិច យើញ"មកំពែងព្រះបរមរាជវាំង និងប្រាង្គប្រាសាទ
ភ្ជិចញាច រិចត្រដោយកញ្ចាច់រចនាផ្សង ។ មានបៃបតាពងនិង
កំពូលមណ្ឌលខ្ពស់ត្រដែតទេរឹងទៅលើ ។

កប៉ាល់បើកឃ្លាតពីវត្តឧណ្ណាលោម ឆ្ពោះត្រង់ទៅឯដើង
ហើយ ។ ព្រះសុរិយា ក៏លិចស្រឹមបាត់ទៅ ពេលព្រលប់
ទិតបូលមកដល់ភ្លាម ធ្វើឲ្យស្រអាប់គ្រប់ទិសមួយរំពេច ។
មិនយូរប៉ុន្មាន យប់ងងឹតក៏បូលមកត្រជាងគ្រប់លើដែនពសុធា
មើលអ្វីលែងឃើញទាំងអស់ ។

មុខគួរឲ្យសង្វេគពន់ពេក នៅលើកប៉ាល់ ក្រឡាះហាម-
គង់ ដៃទាំងពីរជាប់ខ្នោះ ខំត្រដរផ្គងទ្បើងនូវអញ្ជលី ក្រាប
ថ្វាយបង្គំលាព្រះបរមរាជាពីចម្ងាយ ។ សេចក្តីស្នេហាជាតិ
មាតុភូមិនិងព្រះមហាក្សត្រ នៅតែជិតជាប់នឹងដួងចិត្តបណ្ឌិត
នេះជាដរាប ពុំមានច្រាសចាកឆោឡាបន្តិច ។

ក្រឡាហោមគង់លើកដៃប្រណម្យដោយលំបាក ទឹក
ភ្នែកហូរស្រោកផ្កាក់មកលើដើមទ្រូង សរឆ្រងសរឆ្រៃ អង្គុយ
សញ្ជឹងគិតថា : "ខ្ញុំអាត្មាអញ ទៀងជាស្ងាប់ទឹងដៃបាវ៉ង
កងគ្រានេះហើយ ។ ប្រសៃហើយជាខ្មុំអញពុំបានជ្រាបផងទេ ។
គំនិតនេះជាសេចក្តីព្រាបាទរបស់ជាតិបរទេស ធ្វើដោយអាថ៌
កំបាំង ពុំឲ្យនរណាដឹង" ។

សញ្ជឹងគិតដូច្នេះហើយ ក្រឡាហោមគង់ក៏ផ្ញើតទុកាស
ប្រសិទ្ធិពរថ្វាយបង្គំច ។ ចំពោះព្រះភូសក្ក ថា : សូមឲ្យព្រះអង្គ
ស្ថិតនៅកងសិរីរាជសម្បត្តិប្រកបដោយសុខុមាលភាពនិងវឌ្ឍន
ភាពដ៏រុងរឿងតទៅ ។ ខ្ញុំបូលព្រះបង្គំជាខ្ញុំពុំបាននៅយក
អាសាព្រះអង្គទៀតទេ មុខជានិពសប្រាសចាកពីព្រះអង្គកុំ
ពេលឥឡូវនេះហើយ ។

សំដួរ

๑- ចូរពន្យល់ពាក្យ អរុណរដ្ឋី, ក្រាដ្ឋក្រាសាទ
ព្រះភូសក្តិ, សុខុមាលភាព ។

๒- ចូរកែវចនសព្ទ នៃពាក្យទាំងនេះ ៖
អរុណរដ្ឋី, ពស្តុជា, ប្រណម្យ ។

๓- ចូរឆ្លើយអធិប្បាយអំពីមុខងារ សំរេចអំពី
វេស់សកម្មកិរិយា និងអកម្មកិរិយា
ហើយចូរស្រង់ក្នុងពាក្យនេះដាក់ដោយឡែក
ពីគ្នា ព្រមទាំងកិរិយាសព្ទដែលអាចប្រើ
បានក្នុងប្រភេទទាំងពីរ ប្រសិនបើមាន ។

មធ្យមសិក្សាបឋម
(លើកទី ๒ ថ្ងៃ ๒๐ · ๖ - ๖๐)

កំណត់ចំណាំ

๑- អក្ខរាវិរុទ្ធ.-
- ជិដ្ឋូករ (អានថា ជីន - នាក់ - ករ ឬ ជិ - នាក់-

ករ) សរសេរ ទ្វិ និង ជ ។ ក៏ មានរៀ

ងាងចុង ។

- **អរុណា** (មិនមែន អ្វីរុណាទេ) សរសេររៀ និង

ណា ។

- **អចសាធ** (សាធ សរសេរ សា និង ធ) កុំ

ប្រែន័ងពាក្យ សាន្តត្រាណ, សុខសាន្ត,

កម្សាន្ត (មកពីកម្សាន្ត) ។

- **ក្រៀមក្រំ** (ក្រំ មិនសរសេរ ក្រែ និង ម ទេ)

គេថា ក្រំខ្លួន, ក្រំចិត្ត ។ កុំប្រែន័ង ក្រម

(ក្រិត្យក្រម, ក្រមការ) ។

- **ក្រោសាធ** (កុំប្រែន័ង ប្រសាទ) ។

- **កប៉ាល់** (មិនមែន កុំ ប៉ា"ល់ ដូចប្លែកទេ) ។

- **ឧណ្ណាឡោម** (សរសេរ ឧ ណ្ណ + ឡោម ។

អានថា ឧ ណ្ណ + ឡូម) ។

– ស្រីង (អាចសរសេរ ស្រែម ក៏បាន) ។

– ចចឹត (ជំពូ សរសេរ ជ និងស្រៈ ឹ) ។

– អញ្ជលី (អាចសរសេរ អ្នញ្ជលិ ក៏បាន ។ ខ្លះ សរសេរ អ្នញ្ជលិ) ។

– ដួងចិត្ត (មនសរសេរ ខ្លួង ដូច្នេះទេ) ។

– បណ្ឌិត (កុំច្រឡំ នឹង បណ្ឌិត្យ ដែលជាគុ. ប្រ នាម ប្រែថាការ:នៃបណ្ឌិត, សភាព, ឋាន, ទី, តំណែងនៃបណ្ឌិត ។ ខ. បណ្ឌិត្យសភា, ពុទ្ធសាសនបណ្ឌិត្យ) ។

– ប្រែណាម្យ កិ. (សរសេរ ណា និង ម្យ ។ កុំច្រឡំនឹង ប្រែណាម ជានាម) ។

๒- វេវចនសព្ទ នៃពាក្យ:

๑- អនុណារទ្ធី (មកពីអនុណា + រទ្ធី ប្រ រស្មី) = រស្មីព្រះអាទិត្យពណ៌មាស) ។

- សុរិយារង្សី, ទិនារង្សី. អាទិច្ចារង្សី, ស្បូរារង្សី, គាណុ
រង្សី, រវិរង្សី, ហរិរង្សី ។

- អរុណប្រភា, អរុណារស្មី ។

๒- ពស្ធុធា (មកពី សំ. ថា. វសុធា. វ>ព ថា
ពសុធា) ។

ផែនដី, ពិភពលោក, ពស្ធុន្ធរ, វស្ធុន្ធរ,
បថវ, ប្រថព, មណ្ឌលជ, ធរណ, មហ,
មេទនី, វិស្ធុន្ធរី, រតនគព្ភ ។

๓- ប្រណាម្យ (កំ. លើកកម្សាន់អញ្ជលីសំពះ)

-លើកដៃសំពះ, សំពះ, ផ្ងើអញ្ជលីកិច្ច, អញ្ជលី
ទនកិច្ច, វន្ទនកិច្ច, ថ្វាយបង្គំ ។

๓- សធិសសព្ទ នៃពាក្យ :

๑- វិញ.-

- **និញ្ច** : នំ ប្រែថា ទៀត, ដូចដែល (មកវិញ, ទៅ

វិញ); ជាជាង, ស្រលជាង, ខេតើ, (យក
នេះវិញ); ថែមទៀត, ម្ដងទៀត, ដដែល
ទៀត (វិញទៀត) . . .

– ទេញ កិ. ប្រែថា ត្រចាញ់ចញ្ចើមចូង (វេញវៀរ);
រួមគំនិតគ្នាតែមួយ (វេញគំនិតគ្នា) ។

២– អាបិ.–

– អាថិ ជានាម (អាច័ក់ចាំង) ។

– អាធិប្ប គាទំ ជានាម ប្រែថា ដើម, ខាងដើម, ដើម
ដំបូង (ខ. មានដូច្នេះជាគាទំ, ដើមគាទ៍, នាំ
គាទ៍) គេសរសេរ អ្នាធ្យ័ក្ខាន ។

៣– ឆរ.–

– ឆរ ជានាម (មកពី សំ. ច្បា. នរ) ប្រែថា មនុស្ស
ជន (នរណាហ្នឹង!) ។

– ឆី ជាន. សំរាប់ប្រជ្ញនពាក្យ ន្ទុះ, ឯណោះ (ន្ទុះន៍!
ឯណោះន៍!) ។

๔- សម្បត្តិ.-

- **សម្បត្តិ** ជានាម ប្រែថា សេចក្តីសម្រេច, ការ-សមប្រកប, សេចក្តីសុខ, លំអ, ទ្រព្យ, ធន-ធាន (មានសម្បត្តិ, សម្បត្តិសម្បូណ៌) ។

- **សម្បទា** (ឬ សម្បទ) ជានាម ប្រែថា ការដល់ព្រម, ការសមប្រកប (គុណសម្បទ) គេអាចសរសេរ **គុណសម្បត្តិ** ដូច្នេះក៏បាន។

๕- រុង.-

- **រុង** ជាគុ. ប្រែថា ធំ, ដែលចំរើន (ភពរុង, ភព-ឆ្នាំរ, នាអ្នករុងរកឆ្នាំរ) ។

- **រុងរឿង** ជាគុ. ប្រែថាភ្លឺត្រចះ, ឆើត ។

- **រុងរោចនិ** ជាគុ. ប្រែថា ដែលរុងរឿង, ភ្លឺផ្លូក, ពណ្ណរាយ) ។

- **រុងរាំង** ជាកិ ឬគុ.វិ. (ធ្វើរុងរាំង) ។

- **រុង់** ជាកិ. ប្រែថា បង្ហុង់ចំ, ឈប់បង្ហុង់ (រង់ចាំ

បន្ទិចសិន) ។

- **រង់ចាំ** ជានាម គឺឈ្មោះពេលមួយកើតត្រង់ចុង ម្រាមដៃ ដើង បណ្តាលឲ្យឈឺចាប់ពីតខ្លាំង ។

- **រឆ្គ** ជានាម គឺឈ្មោះដំរីមន្ទ័ង (ដំរីឆ្គ)

- **រឆ្គៈ** ជានាម ប្រែថា ការរីករាយសប្បាយ, ល្បែង របាំ, ល្ខោន (រឆ្គសាល, រឆ្គភូមិ) ។

x

x x

ទី៧- យុវជនខ្មែរ

យុវជនខ្មែរទាំងអស់ គេះប្រុសក្តី ស្រីក្តី ជាកម្លាំង មួយផ្នែកយ៉ាងសំខាន់ ក្នុងការបម្រើប្រទេសជាតិមាតុភូមិ ។ យុវជនយើងត្រូវតាំងសតិសម្បជញ្ញៈឲ្យភ្ញាក់រលឹកជានិច្ច ព្រម ទាំងមានសតិអារម្មណ៍ខ្ជាប់ខ្ជួនប្រុងប្រៀងគ្រប់ពេលវេលា តែត្រូវមាន សន្ដានចិត្តចេះសន្ដោស មានអធ្យាស្រ័យ ចេះសុខទុក្ខគ្នា ចេះសាមគ្គីជិតស្និទ្ធ ស្រឡាញ់រាប់អានរាក់ទាក់ មិនប្រទូស្ត ប្រឆ្រែមថមើលងាយយុវជនដទៃ មិនសេពគប់ស្នេហ្គ្រស្នេហមជា

មួយនឹងមនុស្សពាលអបលក្ខណ៍ និងមិនប្រព្រឹត្តល្អផងពាលា
ដែលនាំមកនូវទោសពៃរ៍ដល់ខ្លួនឡើយ ។

នៅតាមជនបទស្រែចំការ ឬនៅតាមរោងចក្រឧស្សា-
ហកម្ម យុវជនជាកសិករ ឬជាកម្មករ ត្រូវបញ្ចេញសមត្ថភាព
ឲ្យអស់ពីចិត្ត ប្រឹងប្រែងរៀសរៃប្រកបការងារ ដែលជា
គាត្រូវតែប្រសប់ខ្លួន មិនស្អាក់ស្អើរតួញ្ញែរ ដោយខិតខំបង្កើត
ផលិតផលគ្រប់ជំពូក ឲ្យបានសម្បូណ៌ហូរហៀរប្រើនជាអានេក-
ឬការ ដើម្បីសាងសង្គមជាតិឲ្យបានចម្រើនលូតលាស់ធាម
រហ័សទាន់សម័យនិយម ។

នៅតាមអគារសិក្សា យុវជនជាសិក្ខាកាម ត្រូវតែព្យា-
យាមរៀនសូត្រសព្វសាស្ត្រវិជ្ជាតាមដោយក្រិត្យក្រម ដើម្បី
បណ្តុះនិស្ស័យវាសនាបស់ខ្លួន ឲ្យទៅជាអ្នកចេះដឹងឈ្លាសវៃ
ឬជាអ្នកច្រាជួបណ្តុំតយ៉ាងចំណាន(១)ក្នុងពេលអនាគត ។

នៅក្នុងគ្រាអាសន្ន ដែលមានខ្មាំងសត្រូវបូលលុកលុយ

---

(១) ត្រូវហ៊ា ដំនាញ វិញ ត្រឹមត្រូវជាង ។

ប្រទេសជាតិ យុវជនទាំងអស់ត្រូវតែធ្វើពលីកម្មបេញ្ចូតយុទ្ធព្រះ
ពារយ៉ាងអង់អាចជាមួយបច្ចាមិត្ត លុះត្រាតែជ័យជំនះជាក
ដំយជាអវសាន ។

យុវជនខ្មែរមិនត្រូវបណ្តែតបណ្តាយ ធ្វើឲ្យជីវិតមានតម្លៃ
របស់ខ្លួន ដែលប្រៀបបាននឹងបុប្ផាកំពុងរីកស្គុសស្គាយផ្សព្វ
ផ្សាយគន្ធពិរោះនោះ ឲ្យស្រពោះស្រពោនទៅវិញបាន។ឡើយ ។
ដោយសារកម្លាំង(២) រឹងប៉ឹងយ៉ាងប្រត្បាក្បៃនៃយុវជននេះ
ប្រទេសកម្ពុជានឹងបានទទួលអាវុធមិ ព្រមទាំងវឌ្ឍនធម៌ជាតិ
ថេរចីរកាលយូរអង្វែង ដូចមហាប្រទេសស៊ីវិល័យនានាក្នុ
សាកលលោក ។

សំណួរ

១- ចូរពន្យល់ពាក្យ *សតសម្បជញ្ញ:, សមត-
ភាព, ភាតព្វកិច្ច, ពលីកម្ម, ប្រត្បាក្បៃ* ។

---

(២) សុំអានឧទ្ទាន = (introduction សម្រាប់បោះពុម្ពគ្រាទី ៥ ឆ្នាំ ១៩៦៨ របស់សម្តេចព្រះសង្ឃរាជ ទំព័រ (ជ) ក្នុងរឿបនានុក្រមខ្មែរភាគ ១) ។

២- ចូរអធិសេសនិសេសឬ នៃពាក្យ "ការ" ។

៣- ចូរឆ្លើសម្ពន្ធពាក្យ ដែលមាននៅក្នុងប្រយោគ "អ្នក
សិក្ខាកាម ត្រូវតែព្យាយាមរៀនសូត្រសព្វ
សាស្ត្រវិជ្ជា" ។

មធ្យមសិក្សាប័ត្រ

លើកទី ១ ថ្ងៃ ៦ . ៣ . ៦១

កំណត់ចំណាំ

១- អក្ខរាវិរុទ្ធ ·-

- **កម្ចាំង** (ត្រូវសរសេរតម្រួត ព្រោះមកពី ខ្ចាំង ។ ពីមុនអាចសរសេរជា កំលាំង ឬ កំឡាំង ដូចគ្នាបាន) ។

- **បង្រៀម** (ត្រូវសរសេរតម្រួត ព្រោះមកពី ប្រើ ពីមុនអាចសរសេរ ប៉ើរ ។ (ន. ន. ។. ភាគ ១ ថ្មី ទំព័រ ៥៥៥) ។

- រលឹក (អាចសរសេរ រឭក ជាន) ។
- អារម្ម៉ណ៍ (កុំប្រឡំនឹង អារម្មកថា, បារម្ភ) ។
- ឧត្តុង្គឧត្តម (អាចសរសេរ ឧដុង្គឧត្តម ជាន) ។
- សន្ដាន-សន្ដោស (សរសេរប្រកបនឹង ជ មិន មែននឹង ណ ទេ) ។
- បរិសុទ្ធ (គុ) ខុសគ្នានឹង បរិសុទ្ធិ (ជានាម) ។
- ហ្មត់ហ្មង (អាចសរសេរ ម៉ត់ម៉ង ជាន ។
- ស្ងិទ្ធ (សរសេរ ស្ងុំ នឹង ទ្ធ) ។
- មិត្ត (អាចសរសេរ មិត្រ ជាន) ។
- តក្កិ (អាចសរសេរ ភ័ក្កិ ជាន) ។
- ប្រែប្រួស្ដ (អាចសរសេរ ប្រែប្រួស ជាន) ។
- ស្ងប់ត្រួស្ងាតឥង (សរសេរ ស្ងប់ នឹង ត្រ, ស្ងាត នឹង ឥ) ។
- ខែ្មរ (សរសេរ ខែ្ម នឹង រ) ។

– **ដំពូក** (អាចសរសេរ បុំពូក ជាន) ។

– **អាសន្ន** (សរសេរ ស ន៑ធ ក្ន) ។

– **តម្លៃ** (មិនសរសេរ តំលៃ ឬ ដំថ្លៃ ដូច្នេះទេ ។ មកពីពាក្យ ថ្លៃ ត្រូវសរសេរតម្រួត) ។

– **ចម្រើន** (ត្រូវសរសេរតម្រួត ព្រោះមកពីពាក្យ ច្រើន ។ ពីមុនសរសេរ បុំរើង ជាន) ។

– **ចិរកាល** (គេអានថា ច្រែកាល ។ គេសរសេរ បីរ កាល) ។

– **បិតរថេរ** (បិត សរសេរទឹង ប ។ បែរ សរសេរ ទ៑ឥ ប) ។

– **សាកលលោក**(អាចសរសេរ សកលលោកជាន)។

២- សន្ធិសង្ខ្យ នៃពាក្យ :

១- ប្រមាប :

– **ប្រយោជ** ជានាម ប្រែថា ការបង្កើតបង្កើនគេ, ការ

មើលងាយគេ ។

- **ប្រមោជ** ជានាម ប្រែថា ការក្លែបស្មានតឿ, ឆ្មៃស ស្មានតឿ ។

- ជាកិ. ប្រែថា ក្លែប, ឆ្មៃស, ប្រហែស (ជនណាប្រមាទ ជនខានុះទុកដូចជាបុគ្គលស្លាប់) ។

២- **ការ** :

- **ការ** ជានាម ប្រែថា អំពើដែលត្រូវធ្វើ (ធ្វើការ, មានការ) ។

- **ការ** ជានាម គឺពាក្យសំពាប់ប្រើជាកត់ខាងដើមពាក្យដែលជាកិរិយាសព្ទផ្សេងៗ (ការសំពះ) ។

- **ការ** ជាកិ. គឺមូរសរសៃសូត្រ (ការសូត្រ) ។

- **ការ** ជាកិ. ប្រែថា បិទបាំង, កំងក, ឃាត់ខាំង (ការមិនឲ្យសត្រូវចូលមក) ។

- **ការ** ជាកិ. គឺរៀបចំផ្សំផ្គុំបុរសនិងស្ត្រី ឲ្យបានគ្នា

ជាប្តីប្រពន្ធ (ការភូន, ការចៅ) ។

– **ការណ៏** ជានាមប្រែថា ហេតុ, ដំណើរ (សេចក្តីពយការណ៍) ។

– **ការ** ជានាមប្រែថា បំពង់សម្រាប់ជាក់ទឹក (កាទឹក) ។

– **ការ** ជាកិ. គឺសរសៃអស់យដ្ឋាន ឈ្មោះអ្នកដែលនឹងទ្រួលសំបុត្រនៅលើស្រោមសំបុត្រ (កាខ្ទង់សំបុត្រ) ។

๓– ភព :

– **តព** ជានាម. ប្រែថា សេចក្តីចំរើន, ដំណើរ, កើត (នៅក្នុងកពរនេះ) ។

– **តប់** ជាកិ. ប្រែថា ដួប, ប្រទះ, ប្រសព្វ (តប់-ប្រសព្វ) ។

x

x x

ទី៨.- សិលាប្រាសាទ និង ខ្មែរបុរាណ

ប្រទេសកម្ពុជា ជាប្រទេសក្នុងតំបន់ដែលសម្បូរដោយសិលាប្រាសាទ ដែលជាគំរូដ៏ពិសេសនៃស្នាដៃបុរាណរបស់ខ្មែរជន ពីក្នុងបុរាណសម័យ ។ ប្រាសាទទាំង ដែលមានលម្អដ៏បវរ ស័ក្តិសមឥតមានពីរនោះ គឺប្រាសាទនគរវត្តដែលសព្វថ្ងៃហៅ ក្បាយជាអង្គរវត្ត ។ សិលាប្រាសាទនេះមានក្បួរក្បាច់រចនា ដ៏បណ្ដាច់អស្ចារ្យ ក្នុងថាតែមនុស្ស ពោះទាំងទេពតា ក៏គង់ និយមការសរសើរពុំខាន ។

តាមពាក្យបរម្បរថា ព្រះពិស្ណុការមកជួយសាង តែបើ តាមសិលាចារឹកជាភ័ស្តុតាងថា ជាការស្នាដៃនៃពួកពាជវង្សក្តី ជាមនុស្សជាតិខ្មែរសុទ្ធ ជាពួកកុលបុត្រ តក្កវិទ បេះពិនិត្យកិច្ច ការ ជាអ្នកបរិបូណ៌ដោយសិល្បវិទ្យាសាស្ត្រ សាងកិច្ចការ ព្រះកេតុមាលាក្បត្រាធិការជខេមរជាតិ ។

ខេមរជនសម័យបុរាណ ជាអ្នកមានអធ្យាស្រ័យគម្ភីរភាព

ពេញចិត្តនឹងការសិក្សាបំណែនវិជ្ជា ទាំងផ្លូវលោក ទាំងផ្លូវធម៌
ហើយឧស្សាហ៍ស្រែកស្រែទេញ រៀនទន្ទេញដោយការម៉ឺងម៉ាត់
ប្រយ័ត្នក្រែងសាបសូន្យការចេះដឹង ព្រោះហេតុហ្នឹងហើយបាន
ជាខេមរជនបុព្វបុរសរបស់យើងធ្វើសិស្សាច្រើនសែនប្លែកៗអនេក
អនន្តអស្ចារ្យ ស្ទើរតែនឹងគណនាត្រាប់ឲ្យសព្វគ្រប់ពុំបាន ។
ជាតំខែរកូនដំនាន់បុរាណ មិនមែនចេះត្រឹមតែការហត្ថ-
កម្មប៉ុណ្ណោះទេ សូម្បីតែកវីជ្ជា និងវិទ្យាអក្សរសាស្ត្រ ព្រមទាំង
សល្យសែរ ក្បួនច្បាប់ ក្រឹត្យក្រម តុរង្គតន្ត្រី កមានល្បីថាចេះ
គ្រប់មុខ ទុកបែបបទជាគ័ស្តុតាងឲ្យយើងឃើញច្បាស់ជាមួរ
សិលាចារឹកដ៏វិចិត្រ មានតែងគាថាជាពាក្យកាព្យឆន្ទសំស្ទើត
ដោយពិនិត្យពិច័យ ជាសម្ងាដៃនៃបណ្ឌិតកវីអ្នកប្រពន្ធ មាន
លក្ខណៈត្រឹមត្រូវគ្រប់គ្រាន់ ឥតមានវិបត្តិល្អៀងឃ្លៀងឃ្លាត
ខាតខុសឡើយ ។

សំណួរ

១— ចូរពន្យល់ពាក្យ ទាំងឡាយនេះ : តក្កវិទ,

គម្ពីរភាព, ស្រាស្រេចេញ, ក្រិត្យក្រម, តុប្ប
តន្ត្រី, សំស្ក្រឹត ។

២- ចូរអ្នកសង្កេតប្រៀបធៀបគ: "ខេមរជនសម័យ
បុពណ ។ល។ គណនាត្រាប់ឲ្យសព្វគ្រប់
ពុំបាន" ។

៣- មានអ្នកខ្លះពោលថា ខ្មែរមិនអាចកសាង
ប្រាសាទឲ្យមានលម្អយ៉ាងនេះទេ គឬស្រាស
ជាព្រះពិស្ណុការមកជួយសាង, ខ្លះទៀតឆ្លើយ
ថា : គ្មានព្រះទេពតាណាជួយសាងទេ គឺ
ប្រាកដជាស្នាដៃ នៃពួកបុព្វបុរសខេមរជាតិ
យើង ។ តើអ្នកយល់ដូចមេចចំពោះមតិ
ទាំងពីរខាងលើនេះ ? ។

មធ្យមសិក្សាប័ត្រ
(លើកទី ២ ថ្ងៃ ២៦-៦-៦១)

កំណត់ចំណាំ

๑. អក្ខរាតិរុទ្ធ.-

- **សិលោ** (ន) ឬ (កុំច្រឡំនឹងពាក្យ សីលៈ ឬ សីលោ ចារ, សីលោ ឧស្សត្ត) ។

- **លម្ភ** (សរសេរតម្រង់ ពីព្រោះមកពីពាក្យ ឡភ ឬ ឡព្ភ ពីមុនសរសេរ លំអ ដូច្នេះ) ។

- **ឧពតា** (អាចសរសេរ ទ្វេព្យញ្ជនៈបាន) ។

- **ភ័ស្តុតាង** (អានថា ភ័ស្តុ - តាង; - សរសេរ ភ័ស្តុ - តាង) ។

- **ប្រយ័ត្ន** (យ័ត្ន សរសេរ យ៌ និង ត្ន) ។

- **សម្ភារៈ** (សរសេរតម្រង់ ពីព្រោះមកពីពាក្យ សម្ភ ។ ពីមុនសរសេរ សំណង រៈ) ។

- **អនគ្ឃ** (អាចសរសេរ អ៌ឃ បាន) ។

๒. ន័យរបស់ពាក្យ.-

- **បទរាសក្តិ** (ស.ន.) រុំរឿង ប្រៃសើរសក្តិសម ។

– **ពាក្យបរម្បរា** (ស.ន.) ពាក្យមិនពិត, ពាក្យនិ-
យាយតៗគ្នាពីមាត់មួយទៅមាត់មួយទៀត ។

– **ព្រះពិស្ណុការ** (ន) មកពីពាក្យ វិស្សកម្ម ដែល
ជានាមនៃទេវតា អ្នកមានបំណែះខាងការជាង
ជាអ្នកសម្រេចកិច្ចការថ្វាយព្រះឥន្ទ្រ ។

– **វឌ្ឍកី** (ន) ជាងឈើ (វឌ្ឍកីកម្ម = ការជាងឈើ)។

– **តក្កវិជ** (ន) អ្នកបែនតក្កវិជ្ជា គឺបែនវិជ្ជាត្រិះរិះរក
ហេតុផលដែលបែកឲ្យឃើញច្បាកដ ដោយ
គំនិតខ្លួនឯង (ដូចគ្នានឹងពាក្យតក្កវិញ្ញូ) ។

– **សិល្បីសារ្វស្ត** (ឬសិល្បសាស្ត្រ) (ន) ក្បួន
រៀនសិល្បៈ, បំណែះជាង ។

– **គម្ភីរតារ** (ស.ន.) ភាពជ្រៅ, ជម្រៅ ។

– **ស្រេងារស្រេងេញ្ជ** (ក.) ខិតខំ សង្វាតពេញ
កម្លាំង, ខ្វីឃ្មាត ។

– **ក្រិត្យក្រម** (ស.ន.) (ក្រិត្យ = ច្បាប់ដែល

តែងតាំងឲ្យអនុវត្ត = le kret, le décret ;

ក្រម = បញ្ជាប់ដែលរដ្ឋសភាអនុម័ត ហើយ

ប៉ុន្តែព្រះហស្តលេខានៃព្រះប្រមុខរដ្ឋសំរាប់អនុវត្ត

ជាច្បាប់ = la loi) - ក្រិត្យក្រម = លំដាប់

នៃកិច្ច ។

- **គូរឫគន្លឺ** (ន.) គ្រឿងក្វេងដេញដំផ្ទុំកូត ។

- **គាថា** (ន.) កម្រងវាចាដែលមានវរៈបៀបកំណត់

ដោយខ្សែអក្សរមាន ៤ នឹ្ម គណៈ ឃ្លា ល្បះ ។

- **សំន្តឹត** (ន.) ឈ្មោះភាសាដើមដំបូងបំផុតរបស់

ពួកហិណ្ឌូ ។

៣- សទិសសព្ទ នៃពាក្យ :

១- ស៊ីលៈ-

- **សីល** (ន) ការកាន់ប្តូរប្រព្រឹត្តល្អដោយគោយវាចា

(សីលកថា, សីលគុណ) ។

- **សិល្ប** (ន.) សរសេរបានជា សិល្បៈ ឬ សិល្ប៍

(រៀនសិល្ប៍, សិល្ប៍វិជ្ជា) ។

២- បិដ្ឋ.-

- **ចិត្ត** (ន) (ចិត្តត្រង់, ចិត្តល្អ) ។

- **ចិត្ត** ឬ ចិត្រ (គ. ឬ ន.) ដែលគេចិត្តហើយ, ដែលគេធ្វើដោយផ្ងួតផ្ងង់ (រូបចិត្រ, ចិត្រករ, ចិត្តវិជ្ជា ឬចិត្រវិទ្យា) ។

- **ចិត** (ក.) កាត់ជាចំណិត (ចិតបន្លែ) ។

- **ចិតសិប** (ប. សំ) ចំនួនដប់ ៧ ដង ។

x

x x

ទី៩.- ការហត្ថកម្មនៅវាលសោះខ្សល់

ដើម្បីឲ្យប្រជាពលរដ្ឋប្រកបដោយសុខុមាភាព ឧត្តង ឧត្តម
ពុទ្ធ
សមតាមសម័យបច្ចុប្បន្ន ព្រះបិតាឯកភព្វជាតិ ជាព្រះ
អគ្គមគ្គុទ្ទេសក៍នៃយើង ព្រមទាំងភជរដ្ឋាភិបាល បានពិនិត្យ
ពិច័យរៀបចំឲ្យអនុវត្តន៍នូវផែនការប្រាំឆ្នាំដោយមធ្យត ។

មិនមែនគ្រាន់តែព្រះអង្គទ្រង់ចំណាយកាយពលផ្ទាល់ព្រះអង្គដើម្បីទ្រង់បំពេញការហត្ថកម្មប៉ុណ្ណោះទេ ព្រះបិតានៃយើងទ្រង់ត្រាស់បង្គាប់ឲ្យមន្ត្រីគ្រប់ជាន់ថ្នាក់ អ្នកស្រុក កងរាជពលខេមរភូមិន្ទ យុវជន យុវតី ឲ្យចូលរួមធ្វើការជួនបណ្តាពស្ត្រគ្រប់ទុគ៌ម ជនបទ គ្រប់ភូមិ ស្រុក និងខេត្តនៃព្រះរាជអាណាចក្រ ។

នៅការជ្ឋានៃរាល់សោះខ្សល់ ជារឿងរាល់ថ្ងៃ វេលាព្រឹកព្រាងស្វាងអរុណាទ័យ សូរសំពួរត្រែបានបន្លឺឡើងខ្ទរខ្ទារ ទាំងវៃព្រឹក្សា កម្មការថ្នាប្រញាប់ប្រញាល់គាន់ចបបង្គីគ្រប់ ។ ដៃ ហើយចរចេញទៅបន្តកិច្ចការរបស់ខ្លួន ។ គេកាប់គាស់ដី ក្រោមស្បែរសែង ក្រោមក្បឿង ផ្លែ ឬក្រោមផ្កបន្លែព្រះព្រៃមាក៏ពិតមែន ប៉ុន្តែគេសោមនស្ស សប្បាយរីករាយ ។

ពុះពារការងារឧបសគ្គនានា យកជ័យជំនះលើធម្មជាតិសម្រាប់ជាប្រយោជន៍ជួនប្រទេសជាតិ ។

ព្រោះហេតុហ្នឹងហើយ បានជានៅពេលធ្វើការ គេឮ

សូរសព្ទសំណើចអឺងអាប់ផុសចេញពីការសន្ទនាគ្នា ជាការកំ
ដរនិងលំហែបរិយាកាសជានិន្ន័ ។ ប៉ុន្តែមិនយូរប៉ុន្មាននេះឡើយ
លទ្ធផល គឺផ្នែកនៃការប្រឹងប្រែងនៃកម្មវិធីប្តីគ្រប់មជ្ឈដ្ឋានក៏
បានលេចជារូបរាងឡើង ។

ខ្ញុំបន្តឹកនៅវាលសោះខ្សាច់មានសណ្ឋានធំ បានលាត
លូនសន្ធឹងរូបស្តុកស្តឹងយ៉ាងប្រកបត្បំពោះមុខយើងពាល់គ្នា ។
ពេលនោះសម្តេចត្រង់យាងទៅធ្វើបុណ្យសម្ពោធយ៉ាងអធិកអ-
ធម មានប្រជារាស្ត្រកុះករឈូនរ ចូលមកអបអរសាទរក្រាប
ប្រណិបត្តន៍សំដែងស្វាមីភក្តិបំពោះព្រះអង្គ ។

ក្នុងស្មូនរកថាមួយយ៉ាងវែង ព្រះអង្គបានបញ្ជាក់ប្រាប់ក្មួន
ៗថា “ការសាមគ្គីគាជាធ្នឹមួយ អាចផ្តល់នូវអត្ថប្រយោជន៍
នូវឱ្យនភាពនិងជោគជ័យជូនជាតិ ដូចមានខំនបន្តឹកនេះជា
កស្តុតាងស្រាប់” ។

សំឆ្លូរ

១– ចូរពន្យល់ពាក្យ សុខុមាលភាព, អរុណោ-

ទំយ, អធិកអធម, វិវឌ្ឍនភាព ។

២- ចូរបង្ហាញន័យ នៃពាក្យ "មហា" និង ពាក្យ "ឧត្តម" តើខុសគ្នាយ៉ាងណា ? ឧទាហរណ៍ ។

៣- គាមគំនិត នៃការសរសេរតាមសូត្រនេះ តើ ការហត្ថកម្មមានតម្លៃយ៉ាងណាខ្លះ ?

កំណត់ចំណាំ

១- អក្ខរាតិរុទ្ធ .-

- ហត្ថកម្ម (ហត្ថ សរសេរ ត្រង់ដើម ១ ។ កុំ ច្រឡំ ហត្ថ ន១ ហស្ត ។ ចុះហត្ថលេខា, ត្រង់ឡាយព្រះហស្តលេខា) ។

- ព្រះបិតាឯកឝ្យរាជ្យ ឯកវាជ្យ ជានាម ។ ច្រ ទេសឯក រាជ = រាជ ជាគុណនាម) ។

- មគ្គុទ្ទេសក៏ (អាចសរសេរជា មគ្គុទ្ទេសក៍ ដូចប្លែកបាន) ។

- ពិចិយ (សរសេរ ប័ ន ធ យ ។ គ្មានដើម (ូ)ទេ) ។
- មច្ឆរ្យ (សរសេរ ម-ច្ឆ៍ ន ធ ព) ។
- ទុគ្គិម (អាចសរសេរ ទុរ្គម ដូចគ្នាបាន) ។
- ខែត្រ (អាចសរសេរ ក្សេត្រ ដូចគ្នាបាន) ។
- ក្រីកក្រោច (ក្រោង ខុសពីក្រៀងលាន) ។
- សូរសព្ទ (ស័ព្ទ អាចសរសេរ សព្ទ ដូចគ្នាបាន)។
- ខ្លួនខ្លាង (សរសេរ ន ខាងចុងដូចគ្នាទាំងពីរពាក្យ) ។
- សោមនស្ស (សរសេរ ស៊ ដើម -ស្យ) ។
- ឆ្ងាង (មាន ន ខាងចុង) ។
- ធម្មជាតិ (សរសេរ ធម្មជាត ដូចគ្នាបាន) ។
- សង្រ្គាម (សរសេរតម្រួត ពីព្រោះមកពី ស្រាប់ ពីមុនសរសេរ សំរាប់) ។
- កំណរ (សរសេរ ន ចុង ។ ពីមុនសរសេរ កម្ម ដូចគ្នាបាន តែឥឡូវឈប់សរសេរយ៉ាងនេះ ហើយ) ។

- **ឈំរំហា** (អាចសរសេរ រំហែ ដូចខ្លះបាន ។ គ្មាន រ ចុងទេ) ។
- **ឯិរន្តរ៍** (សរសេរ ឯិរឯិរ ដូចខ្លះបាន) ។
- **ឈន្ធឈស** (ឈ ទ្វេ សរសេរគ្មាន (់) ទេ) ។
- **សម្ភោធ** ជា កិ. (ប្រើជានាម សរសេរ សម្ភោធ ឬ សម្ភោធ៌ ។ ដូនតាលេខសរសេរ សម្ភោជ ឬ សម្ភោទ្យ ដូចខ្លះក៏មាន) ។
- **អធិកអធម** (អានថា អ:ធិក-អ:ធំ) ។
- **កុះករ, ឈូឆរ, អបរអរ, សាធរ** (ករ, ឆរ, អរ, ទរ សរសេរ រ ចុង) ។
- **ប្រណិបត័តន៍** (សរសេរ ប័-ព័ ន៍ ឯ ន៍) ។
- **ស្វាមីភ័ក្តិ** (អាចសរសេរ ភក្តិ ដូចខ្លះបាន) ។

២- ពន្យល់ពាក្យ :

- **សុខុមាលភាព** ភាពនៃបុគ្គលអ្នកមានសេចក្តី

សុខ, ការដែលធ្លាប់តែស្រណុក ។

- អនុវត្តន៍យ (មកពី សំ. ក. អនុ+ឧទ្ធយ ប្រែថា "ការរះឡើង" ការរះឡើងនៃអរុណ, គឺពេលអរុណរះ, វេលាថ្ងៃរះ ។

- អធិកអធម (មកពីសំ. ក. អធិក = ក្រៃលែង, លើសលែង, លើសលន់, រុងរឿង, ហ៊ឺកហ៊ាត់ +អធម=ថយចាក, ចាកឋាន, មិនរុងរឿង, "រេម៉ះរេម៉ាះ, ភយវង, បន្ទាប់បន្សំ = ខ្មែរប្រើពាក្យនេះចំពោះតែពីធីបុណ្យ ដែលរុងរឿងផង "រេម៉ះរេម៉ាះ របូចរប៉ូកយវង្សខ្លះផង ។

- វិវឌ្ឍនភាព (ក. វិឌ្ឍន: = សេចក្តីចំរើន + ភាវ: = ភាព) ភាពចំរើន លូតលាស់ ។

៣- សន្ធិសម្ព័ន្ធ នៃពាក្យ .

១- អប :

- អប ជា ន. ជាបុព្វបទសម្រាប់រឿងភ្ជាប់ពី

ខាងដើមសព្ទដទៃ មានសេចក្តីថា "ប្រាស
ចាក, ឃ្លាតចាក, ឃ្លាងចាក, ឆ្ងាយ, ទៅឆ្ងាយ,
ត្រឡប់, ត្រឡប់ជា, បែរជា, ផុត, រួចផុត, មិន,
ឥត (អបគតណ៌, អបច័យ, អបទេស, អប
ទ្រព្យ, អបធន, អបមង្គល ឬ អពមង្គល, អប-
លក្ខណ៌) ។

- **អប្បរ** ជា គុ. ប្រែថា តិច, តួប, ស្តួចស្តើង
(អប្បទ្រព្យ, អប្បធន, អប្បបញ្ញា ឬ អប្បប្រាជ្ញ)

- **អរាម** ជា គិ. ប្រែថា ជាត់ប្រាត់កាត់ ឬលុយ
ឲ្យទៅអ្នកទំញ (គេអាប់លុយឲ្យខ្ញុំលើស) ។

- **អរាម** ជា គុ. ប្រែថា ដែលអន់ ឬតិចពន្លឺ, ថយ
លំអ, ទៅក, ទន់ខាប, ខ្សោយ, តិច (អាប់
គំនិត, អាប់ជាតិ, អាប់ម្ខុ, អាប់អ្ម, អាប់អូន
ឬអាប់ខុន) ។

- **អរញ្ញ** ឬ **អរ័ញ្ញ** ជានាម គឺពពកខាប់ ឬ ពពក

ក្រាស់ (មេឃប៉ុះអ័ព្ទ) ។

២- កាំ :

- **កាំ** ជានាម ប្រែថា ថ្នាក់, ជាន់ (កាំផះណ្តើរ, កាំ. វេះ)

- **កាម្ម** ជានាម ប្រែថា អំពើ (វេរកម្ម, កម្មករ) ។

x

x x

ទី១០- . . . . . (១)

នៅពេជជានីក្នុងពេញ្ញ មហាជនប្រុសស្រី ក្មេងចាស់និង ពួកអ្នកទេសចរបរទេស បាននាំគ្នាទៅមើលព្រះរាជពិធីអុំទូក លយប្រទីបផ្សាលា និងសំពះព្រះខែ ដែលបានរៀបចំធ្វើឡើង យ៉ាងអឹកធឹកជាងពីឆ្នាំមុន ។ ។ ក៏ឮប្រណាំងទូកនេះ ជា កម្មាមួយជធអស្ចារ្យនៅប្រទេសកម្ពុជា មិនឲ្យបាត់បង់ទៅណា

(១) អត្ថដើមគ្មានឈ្មោះទេ ។ សៀវភៅសហជីវិន ជឹម - ទ្រ៧ ឈ្មោះ សរសេរតាមសូត្រឌីប្លូម បេញ្ញាំ ១៩៦៣ បានពិគ្រោះនិងខ្ញុំដាក់បំណងដើងថា "ព្រះរាជពិធីអុំទូកលយប្រទីប" ។

សាធារណៈរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
លេខចុះ: ...
លេខបញ្ជី: ...

បានរក្សាទុកបំនួនប្រទេសតរួមកាហើយ ។

នៅកងសួនបារជិរបត្រដោយទឹងយ៉ាងល្អស្អាត ទឹង
ដោយរុក្ខជាតិពណ៌ផ្សេង ។ នៅលើផ្ទៃនៃស្មៅយ៉ាងខៀវខ្ចី
បញ្ចាំងដោយពន្លឺអគ្គិសនីដ៏ភ្លឺថ្លា មហាជនប្រុសស្រីតុបតែង
ខ្លួនយ៉ាងល្អគ្រប់ ៗ គ្នា ឈរនិងដើរវេកមៀងមើលប្រទិបនិង
កាជ្រួចដែលកំពុងតែសំដែងនូវលម្អដ៏ក្រណាលមហាគង្គានិង
ព្រួដ៏តណ្ណាលអាកាសវេហាស៍ ហាក់បីដូចជាពួកទេវតានាំគ្នា
ដើរលេងកងសួនទេវាលោក ។

ដំនោរខែកត្តិក ក៏បានបក់មកអំពីទិសខាងដើមយ៉ាង
រំភើយៗ កម្មាត់អស់ពាំងសេចក្តីសុះសាប់ បង្គតអស់ពាំងញើស
ហើយបបោសអង្គែលហាទយវត្តនៃមហាជនឲ្យអស់ នូវ
សេចក្តីខ្នុកខ្នែរយ៉ាងគ្រប់យ៉ាង ដែលមានមកពីថ្ងៃមុន ។
ដល់ពាក់តណ្ណាលអធ្រាត្រ សំឡេងសកវាទំនៅព្រះ
ដំណាក់ផែ ក៏បានបន្លឺឡើងដោយបទយ៉ាងសែនពីរោះ ហាក់
បីដូចជាទឹកអម្រឹត ដែលទេពតាយកមកស្រោចស្រប់បេះដូងនៃ

មហាជនច្រើនកុះករ ត្រជាក់ត្រជុំក្សេមក្សាន្ត សម្បូរ
សម្រន្តក្នុងអារម្មណ៍ដ៏សែនមនោរម្យឥតឧបមា ។
មហាជនសរសើរស្ទើរតែពាល់មាត់ ដល់ពាជរដ្ឋាភិបាល
សង្ឃ ដែលបានខិតខំរៀបចំទីក្រុងភ្នំពេញ ដោយមានវាចា
ថា ពាជនីយើង បើសម្តេចព្រះបិតាទ្រង់គង់នៅជាព្រះអគ្គ-
មគ្គុទេសក៍ជាពហុណា ជាកថានាះនឹងបានទៅជាទីក្រុងមួយយ៉ាង
ល្អឆើតឆាយ ។

សំណួរ

๑. ចូរពន្យល់ពាក្យ ទេសចរ, ប្រទីបផ្កាលា, ឮដីកណ្តាលអាកាស, ហាទយវត្ត, ទឹក-
ត្រី, អម្រឹត, សែនមនោរម, អគ្គមគ្គុទេសក៍ ។

๒– ចូរបង្ហាញន័យនៃពាក្យ "មហា" និងពាក្យ
"ឧត្តម" តើឧស្សគាយ៉ាងណា ? ឧទា-
ហរណ៍ ។

๓– ចូរសង្ខេបន័យពាក្យត្រង់ឃ្លា : "មហាជនប្រុស

ស្រីតុបតែងខ្លួនយ៉ាងល្អគ្រប់ៗគ្នា ឈរនិង
ដើរវេក" ។

មធ្យមសិក្សាប័ត្រ
លើកទី ៣ ថ្ងៃ ៩-៣-៤២(១)

កំណត់ចំណាំ

១- អក្ខរាវិរុទ្ធ -

- ឆេសចរ (ជាទាម. *គឺជនអ្នកធ្វើដំណើរលំហែ*
កម្សាន្ត) ។ *កុំច្រឡំនឹង* ទ្វេសបរណ៌ *ជា*
នាម ប្រែថា ការធ្វើដំណើរកម្សាន្ត ឬឈ្មោះ
ក្រសួង ។ *ក្រសួង* ទ្វេសបរណ៌ ។

- អឹកឆឹក (*សរសេរនឹងស្រៈ ឹ* ។ *ឬអាចសរសេរ*
អ៊ឹកអ៊ឹក ក៏បាន) ។

- សតឥត្ថ (*អាចសរសេរ សតវិត្ថ្រ ដូច្នេះបាន*)។

---

(១) បានដាមានលើកទី ៣ ពីព្រោះលើកទី ៤ ត្រូវធាលោលដោយ"មាន
ឧបសគ្គមិនល្អ ភាលពេលប្រឡងលើកទី ២ នោះ ។

- ប្រែធីប (សរសេរទឹងស្រៈ ី និង ប ។

- លង្ហ (សរសេរតម្រួត មកពីពាក្យ ល្អ ។ ពីមុន

សរសេរ លំអ្ហ បាន) ។

- វេហាស៍ (អាចសរសេរ វ៉ៃហ ដូច្នេះបាន) ។

- ដំណោរ (សរសេរ ន ចុង) ។

- កត្តិក (សរសេរ ត ដើង ត ទឹងស្រៈ ិ និង ក)។

- កម្ហាត់ (សរសេរតម្រួត មកពីពាក្យ ហ្គាត់ ។ ពី

មុនសរសេរ កំហាត់ បាន) ។

- អង្រែវត្រ (អានថា អង្រ្វាត ។ សរសេរ ង្រ្ព

និង ត្រ) ។

- សំណ្ឋៀ (តាម វ. ធ. ខ. ភាគទី ២ ឬ ទំព័រ ១៤២៨ មិន

សរសេរ សម្លែង ដូច្នេះទេ) ។

- សកវាធី (រ៉ាទ្ធី សរសេរ រ៉ា និង ទ្ធី) ។

- ពីរោះ (មិនមែនពិរោះទេ) ។

- អង្រឹត (សរសេរទឹងស្រៈ ឹ និង ត ។ គេអាច

សរសេរ អ្នកប្រើ ដូចខ្លះជាន) ។

- ស្រែរាងស្រែសំ (អាចសរសេរ ស្រែបស្រែព្រួ ដូចខ្លះជាន) ។

- **សម្រួលសម្រាន្ត** (សរសេរតម្រួត មកពីពាក្យ ស្រែល - ស្រែន្ត ។ ស្រែន្ត សរសេរ ធ្វើដើម ត្រូ) ។

- **មណ្ឌារម** (អាចសរសេរ មណ្ឌារម្យ ដូចខ្លះជាន ។

- **មគ្គទ្ទេសក៍** (អាចសរសេរ មគ្គទ្ទេសក៍ ដូចខ្លះ ជាន) ។

១- ពន្យល់ពាក្យ

- **ឧទ្ទេសចរ** (ន) ជនអ្នកធ្វើដំណើរលំហែកម្សាន្ត ។

- **ប្រជាធិបជ្ជាសាស** (ន) ប្រព័ន្ធប្រើនដែលជាក់ពីយ ជាជួរ ជាសង្កាត់នៅស៊ុមប្តូនៅប្រទាសបញ្ជរ អុជភ្លើរឆ្នើងកងការធ្វើបុណ្យជាដើម ។

- **ឮដីកណ្ដាលអាកាស** នៅនាកណ្ដាលអា-
កាស កណ្ដាលលំហាមេឃ ។
- **ហាទយវត្ថុ** (ន) លំនៅរបស់ចិត្ត គឺបេះដូង ទឹក
ចិត្តនេះឯង ។
- **ឱកអរជ្រួតត** (ន.) ទឹកទំពូ ផឹកទៅមិនបេះស្កាប់។
- **សែនចម្រើនរាងម** ជាទំសប្បាយក្នុងចិត្ត, រីករាយ
ក្រៃលែងក្នុងចិត្ត ។
- **អគ្គមគ្គុទ្ទេសក៏** (ន.) អ្នកដឹកនាំយ៉ាងធំ យ៉ាង
សំខាន់ ។ ក្នុងអត្ថបទនេះ សំដៅចំពោះ
សម្តេចព្រះ **ឧរោត្តម - សីហនុ** ព្រះប្រ-
មុខរដ្ឋ បិតាឯករាជ្យ អព្យាក្រឹត្យនិងបូរណ-
ភាពនៃប្រទេសកម្ពុជាយើង ។

៣- **សន្ធិសព្ទ** នៃពាក្យ :

១- ទុំក.-

- **ទុំក** ជាកិ. ជាក់វត្ថុអ្វីក្នុងទីណាមួយដើម្បីឲ្យគង់នៅ

(ទុកទ្រព្យ, ទុកជាក់) ។

– **ទុកចិត្ត** (ជាកិ. សង្ឃឹម, ឥឡឹជាក់ថា (ខ្ញុំទុកបិត្តុលោកហើយ) ។

– **ទុកជា ឬ បើទុកជា** ន. ទោះបី, ទោះជា, សូម្បី, ទោះបីបើ (ការនេះទុកជាជាធំណាក៏ឆ្លៀមិនកើតដែរ) ។

– **ទុក្ខ** (ន.) សេចក្តីព្រួយ, សេចក្តីលំបាក (កើតទុក្ខ, មានទុក្ខសោក) ។

២ - ស័ក្តិ .–

– **សក្តិ ឬ ស័ក្តិ** (ន.) អំណាច, កម្លាំង (អ្នកមានស័ក្តិ, ស័ក្តិតូច ធំ) ។

– **សកម្មាធិ** (ន.) (បទសកវាទ) ។

– **សកម្ម** (គុ.) ដែលនៅមិនស្ងៀម (actif) ។

– **សំកែ** (ន.) កាលសម័យ, យុគ (សកពជ) ។

– **សាកំ** (ន.) យ័ន្ត, អក្សរដែលចាក់ទឹងមួលៗ

ក្នុងសាច់ (គាត់នេះមានសាក់រូបនៅទឹងដៃ) ។

- **សាក់** (កិ.) ចាក់ដោយយ្អុលបញ្ចូលទឹកខ្មៅក្នុងសាច់

(ប្អូលចិត្តចង់សាក់ ខ្ញុំសាក់ឲ្យ) ។

x

x x

ទី១១- ប្រាសាទព្រះវិហារ

ក្នុងចំណោមសិលាប្រាសាទខ្មែរបុរាណទាំងឡាយ ព្រះវិហារជាបូនីយដ្ឋានដ៏វិចិត្រមួយ ដែលមិតយ៉ាងខ្ពស់ត្រដែតលើខ្ពង់រាបស្មើនៃភូមិដងរែកភាគខេត្តកំពង់ធំ ត្រង់ព្រំប្រទល់នៃប្រទេសកម្ពុជានិងប្រទេសថៃ ។

ប្រាសាទព្រះវិហារនេះ បានកសាងឡើងដំបូងបង្អស់ដោយព្រះបាទយសោវរ្ម័នភាគបូងសតវត្សទី ៩ ដើម្បីគុំទ្រសាច្ចារ:ព្រះសិវៈស្នូរ: ។ លក្ខណ:គ្រប់បែបទាំងអស់នៃប្រាសាទនេះ តាំងពីទម្រង់ផែនការ រចនាបថ ឬក្បួរក្បាច់រចនាផ្សេង ។ គឺជារបស់សិល្ប:ខ្មែរសុទ្ធសាធ សូម្បីនៅ

តាមសិលាចារឹកសោត កំតែយើញតែអក្សរខ្មែរនិងសំស្ក្រឹត
ប៉ុណ្ណោះ ។ ភ័ស្តុតាងដ៏ពិស្ដារគាំងនេះ បញ្ជាក់យ៉ាងប្រត្យក្ស
ថាព្រះវិហារជារបស់ខ្មែរពិតប្រាកដ កំប៉ុន្តែដោយសារពួកចក្រ
ពត្តិបារាំង ប្រាសាទព្រះវិហារបែរជាធ្លាក់នៅក្រោមការត្រួត
ត្រារបស់ប្រទេសថៃទៅវិញ តាំងពីសម័យអាណានិគមមកម៉្លេះ
រហូតដល់ប្រទេសកម្ពុជាបានឯករាជ្យវិញហើយ ប្រទេសថៃក៏
នៅតែពុំព្រមប្រគល់ព្រះវិហារមកឲ្យខ្មែរឡើយ ហើយថែម
ទាំងប្រើឧបាយមិច្ឆាចារំលោភបំពានដោយប្រកាន់ថា ប្រា
សាទនេះជារបស់ខ្លួនជាដរាប ទើបតែក្នុង ឆ្នាំ ១៩៦២ នេះ
ដោយស្នាព្រះហស្តដ៏ឆ្នើមនៃសម្តេចឪ ដែលព្រះអង្គខិតខំយ៉ាង
ពេញព្រះសមត្ថភាព ក្នុងការទាមទារដោយសន្តិវិធីនេះហើយ
បានជានៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ១៩៦២ ប្រជាពលរដ្ឋខ្មែរ
ទាំងមូលបានទទួលមហាជោគជ័យដ៏សំបើមអស្ចារ្យ ដោយ
គុណាការអន្តរជាតិបានវិនិច្ឆ័យជាឯកច្ឆន្ទថា ព្រះវិហារជារបស់
ខ្មែរ ។

ដំណឹងដ៏សែនរីករាយនេះ ធ្វើឲ្យខ្មែរទាំងអស់គ្រាក
ខ្ពើងស្រែកជយោឃោសអបអរសាទរទូលព្រះវិហារដែលបាន
រំលត់ទ្បប់មកជាសម្បត្តិរបស់ខ្មែរដូចដើមវិញ ហើយដើម្បី
បង្ហាញដល់សកលលោកឲ្យស្គាល់និងដឹងឮច្បាស់នោះ កាល
ពីថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៦៣ សម្តេចព្រះប្រមុខរដ្ឋព្រះអង្គ
ទ្រង់យាងទៅធ្វើព្រះទស្សនកិច្ចជាផ្លូវការនៅប្រាសាទព្រះវិហារ
ជានិមិត្តរូបនៃមត៌កខ្មែរ ។

សំណួរ

១- ចូរពន្យល់ពាក្យ ព្រះសិខរិស្វរៈ, ម៉ិច្ឆាចារ, ឯកច្ឆន្ទ។

២- ពាក្យ « តិហារ » ត្រូវសរសេរជាក់ត្រឹមត្រូវដែរឬទេ ? ព្រោះអ្វី ? ចូរអធិប្បាយអំពីលំនាំនៃ
ការអានពាក្យខ្មែរឲ្យត្រឹមត្រូវ ។

៣- ចូរឆ្លើយសង្ខេបពាក្យ ទាំងឡាយ ក្នុងឃ្លាដូចតទៅ : "ក្នុងចំណោម . . . . វិចិត្រមួយ" ។

មធ្យមសិក្សាបំប្រែ
លើកទី១ ថ្ងៃ ១ - ៣ - ៦៣

កំណត់ចំណាំ

១- ពន្យល់ពាក្យ .-

- **ព្រះសិខរិនស្វរ:** (ន.) (មកពីពាក្យ សំខរ = "កំពូល, ចុង" + ឥស្សរ: = "ឥស្សរ, ដែលធំ, ជាម្ចាស់លើលោក") គឺព្រះឥស្សរដ៏ជាកំពូលលោក ។

- **មិច្ឆាចារ** (ន.) ការប្រព្រឹត្តខុសអំពើអាក្រក់, មានយានអាក្រក់ ថយថោក ។

- **ឯកច្ឆន្ទ** (ន.) ចំណង់តែមួយ, ចំណង់តែមួយ, ចំណង់ត្រូវគ្នាតែមួយ, ដែលមានចំណង់ត្រូវគ្នាតែមួយ, ដែលព្រមចិត្តគ្នា ។

២- អក្ខរាតិរុទ្ធ.-

- **ឫរ៉ាណា** (អាចសរសេរ ឬរាណ ដូចគ្នាបាន) ។
- **ឋិត** (អាចសរសេរ ស្ថិត ដូចគ្នាបាន) ។
- **ពិស្តារ** (សរសេរមានរ ចុង) ។

- **ទំបែន** (សរសៃសរមាន រ៉ូ បុង) ។

- **ទរបែនទរសាធន** (អ្នរ, ទ្ធរ សរសៃសរ រ៉ូ បុង) ។

- **មតិក** (សរសៃសរ មរតក ឬ ម្រ៉ែតក ដូរប្តូរបាន) ។

-៣- សធិសសព្ទ នៃពាក្យ :

១- ព្រុំ (កុំសរសៃសរ ព្រុំ)

- **ព្រុំ** ជានាម ប្រែថា ចាវ៉ែតដី (ព្រុំដែន, ព្រុំប្រទល់)។

- **ព្រុំ** ជាគុ. គឺប្រកបក្នុង ឬ បូកបាយអារក្ខិតត្រង់កន្លែង ប្រទល់ក្បាលក្បឿង (ព្រុំផ្ទះ, ព្រុំសាលា) ។

- **ព្រុំ** ជានាម គឺឈ្មោះកម្រាលវិសេសមួយប្រភេទ វិចិត្រដោយពណ៌ និងក្បាច់រចនាផ្សេងៗ (ក្រាលព្រុំ) ។

- **ព្រហ្ម** ជានាម ប្រែថាសេចក្តីចំរើន, ចំណែកចិត្ត ឬ ឈ្មោះទេវតាដែលកើតនៅព្រហ្មលោក (ព្រះព្រហ្ម, ហ៊ានព្រហ្ម) ។

២- ទារ.-

- **ធារ** ឆកិ. ប្រែថា ក្រើន តឿន បន្ទឹងយកប្រាក់តាមកំណត់ដែលត្រូវបេញ, ត្រូវបង់ (ពារ-ប៉ូ ប៉ូ ថ្លៃផ្ទះ) ។

- **ធារ** ឆនាម គឺឈ្មោះសត្វបក្សីស្រីកមួយមានទ្រម ដើងជាប់គ្នា (ពាស្រុក, ពាព្រៃ) ។

៣- បទ.-

- **បទ** ឆនាម ប្រែថា សំឡេងសូត្រឬច្រៀង (បទ កាកគតិ, បទពាក្យ ៧) ។

- **បទ** ឆនាម ប្រែថា ហេតុ, ចំណែកជាគ្រឿងដល់, ផ្លូវ, ស្នាមជើង (បទអង្ក, ធម្មបទ, សិក្ខា-ប៉ូ បទ) ។

- **បត់** ឆកិ. ប្រែថា ត្រឡប់តាមទំនង (បត់ដៃ, បត់ខោអាវ) ។

- **បថ** ជានាម ប្រែថាផ្លូវ (គរិយាបថ, ដលបថ, កម្មបថ) ។

- **បត់** ជានាម ប្រែថា ផ្នាំដ៏ពូនបូគួរនឹងកំណាត់សំពត់ (ព្រះបត់) ។

- **បទ** ជានិបាត ប្រែថា ដ្បិត (ប្រពន្ធយើញ្ញយាត់ទៅប្តីមិនត្រូវថាកុំអ្នក ឯងខឹងលោភយធាក់ដោយបំពួងបំពុងបទបានស្រា) ។

x

x x

ទី១២- ឋូចេះភាសាមនុស្ស

ព្រោសាទសិលាខ្វែរតាំងប៉ុន្មាន សុទ្ធសឹងតែចេះភាសាមនុស្ស ។ ចំពោះពាក្យនេះ អ្នកផងមួយជាមិនជឿជាជាប់អហង្ការ ព្រោះថា ឋូជារតនសូម្បីតែគេគោះវាដោយដំបងកំដោយ កំរាមិនលាន់សូរដែរ ។ បើដូច្នេះ ហេតុអ្វីកថាឋូចេះភាសាមនុស្ស ?

មែនពិត អ្នកមិនដែលឮថ្នូរនិយាយ ពីព្រោះអ្នកយល់ថា ឫពណ៌កណ្ដាំងឆ្ងាយនោះបានមកពីខ្យល់តាបឆ្អឹងឲ្យ ឬមក ពីព្រះពិស្ណុការកសាងឲ្យ ។ ប៉ុន្តែបើអ្នកតាំងចិត្តរៀនឲ្យស៊ាប់ ជាក្បួនតិកាំងនេះ ពិតជាស្នាដៃរបស់មនុស្ស ហើយមនុស្ស នោះជាតិជាខ្មែរទៀត នោះឮគ្រប់ដុំនឹងនិយាយរកអ្នក ដោយ រីករាយក្លាម ។ កុំចាំបាច់និយាយថ្នូរដល់ទៅកំពូលត្រីសូល់ គាងឃ្យាយដែលខ្ពស់ត្រដឹម ឮដំរៅហាស៍នោះទៀយ សូម្បី តែភីរល្អិតូចមួយ ក៏អាចប្រាប់អ្នកបានថា វិស្សកម្មនិងជាងប្ញូ កងដំនាន់នោះ មានបំណងនិងចំណេះជាអនេកអនន្ត្យហ៊ាងណា ដែរ ។

ប្ញូរអ្នកអញ្ជើញទៅទស្សនាប្រាសាទតាព្រហ្មលេមើល អ្នកនឹងឮសិង្ហនាទីនោះ អកិប្រាយពង្សាវតារនៃប្រទេសយើង កងយុគនោះប្រាប់អ្នក ម្យ៉ាងទៀតអ្នកនឹកអាណាចក្រធម៌ដល់ កំពូលសនាមៃមហានគរមិនខាន ។ ប៉ុន្តែបើអ្នកបានឮថាពាជ-ជានីរបស់យើងដ៏រុងរឿងកងពុកណាកាលនោះ ក្លាយមកជាវិ-

ហារដ្ឋាននៃម្រឹគពាទ្យ ហើយអយ៌អគ្គសិលាសោត កំភ្លាយ
មកជាឋ្នសំលៀងគាំបិតនៃពាលគង្វាលគោ តើបេះដូងអ្នកនឹង
ញាប់ញ័រដូចម្តេចទៅ ? ខ្ញុំសូមបញ្ជាក់ថា សូរស័ព្ទនៃសំដីឋ្ន
នោះ មិនមែនលាន់ចេញពីដងវ័នចិត្តនៃជនណាដែលយកឋ្នោះ
មកធ្វើជាកសិណ ។

សំឌួរ

១- ចូរពន្យល់ពាក្យ ឋុកណាកណ្ហ, យុគ, អា-
ណោចអាធ័ម, ម្រឹគពាទ្យ, កសិណ ។

**២- ពាក្យ«អហង្ការ, វេហាស៍, ភ័ព្ទ, ឋ្ន-
រាណា»** អាចសរសេរបានពីរយ៉ាងដោយ
ឥតខ្វល់ ។ ដូចេះចូរអ្នកសរសេរពាក្យ
ទាំងនោះតាមបែបមួយទៀតនោះ ។

៣- ចូរសង្ខ្ឌពាក្យ ជាប់អហង្ការ, គ, មនុស្ស,
(ស្នាដៃមនុស្ស), កំ (កំអាចប្រាប់អ្នក),
នៃ (នៃប្រទេសយើង) ។

៤- ថ្មបាវត្ត គឺបុះហេតុអ្វីក៏ថា ខេះគាសាមនុស្ស?

មធ្យមសិក្សាប៊ត្រ

លើកទី ២ ថ្ងៃ ៨-៣-៦៣

កំណត់ចំណាំ

១- ពន្យល់ពាក្យ.-

- **បុរាណវត្ថុ** (មកពីបុរាណ + វត្ថុ (វត្ថុប្រែថា វត្ត, ទ្រព្យ, របស់, គ្រឿងប្រដាប់)
= វត្ថុពីបុរាណ (objet antique, objet ancien) ។

- **យុគ** (អាយុ, កាល, គ្រា, សម័យ (époque)។
តាមបុរាណថាយុគមាន ៤ គឺ ទី ១= ក្រឹតយុគ (យុគមាស, អាយុមាស) មានកំណត់ត្រឹម ១.៧២៨ ០០០ឆ្នាំមនុស្ស; ទី ២= ត្រេតាយុគ (យុគប្រាក់, អាយុប្រាក់) មានកំណត់ត្រឹម ១.២៩៦.០០០ឆ្នាំមនុស្ស; ទី ៣= ទ្វាបរយុគ (យុគមានបំនួនលេខពីរ ៗ គឺលេខ

គត់គូ) មានកំណត់ត្រឹម ៨៦៤.០០០ ឆ្នាំ
មនុស្សនិងពី ៤ = កលិយុគ (យុគប្រកបដោយ
ទោស, ប្រកបដោយជម្ងោះ) មានកំណត់
ត្រឹម ៤៣២.០០០ ឆ្នាំមនុស្ស ។

- អារណារចអារដ៏ម (គុ) ស្រងោច ចង្អៀតក្រៃ
ពេក គឺមានចិត្តពោរពេញដោយទុក្ខ តឹងស្ទើរ
ប្រែប្រួល ។

- ទ្រីកពាឡ (ន-) ម្រឹគសាហាវ, កាច (le fauve)

- កសិណ (ន.) រូបតាងជាសំអាង ។

២- អក្ខរាវិរុទ្ធ .-

- អហាទ្ធារ (សរៈសរមានវុចុង) ។

- សូម្ប (កុសរៈសរ សូមប ដូចខ្នះខ្យោះ) ។

- សូរ (សរៈសរមានវុចុង) ។

- ត្រីសូល៏ (សូល៏ សរៈសរ សូ និង ល៏ ។ គេ
អាចសរៈសរ ត្រីសូរ ដូចខ្នះបាន) ។

- **សិង្ហ** (សរសេរ ស ន ង ស្រៈ ិ ហើយ ន ង ង្ហ) ។
- **ពាឍ្យម្ចឹគ** (អាចសរសេរវិទ្ធម្រឹគ ដូចខ្មែរបាន)។
- **ពង្សាវតារ** (ពាវ សរសេរមានវ័ក្ស)។
- **អាវណោចអាធ័ម** (សរសេរ អ្ន មិនមែន អ្នទេ) ។
- **ទាសនា** (មិនសរសេរ វិស្ស ដូចខ្មែរទេ) ។
- **ឫទ្ធាណា** (អាចសរសេរ ប្បញ្ញា ដូចខ្មែរបាន) ។
- **អយ៌អគ្គ** (ពាក្យ ២ ម៉ាត់នេះ សរសេរ ន ង មាន ន័យខ្ពស់ថ្កុំ ។ អ្ន៌ < អយ " បាប, សេពគ្គី ខ្ពើ " ។ អគ្គ ឬ អគ្គ្រ ប្រែថា កំពូល, ខ្ពស់, លើស) ។
- **គង្ហារល** (សរសេរ ន ង ស្រៈ -ា) ។
- **ជង័ន** (សរសេរ ន ង ជ) ។
- **កសិណា** (សរសេរ ក ស ិ ន ង ណ) ។

๓. **សន្ធិសព្ទ** នៃពាក្យ :

១- ពាទ្យ.-

- **ពាឡ្យ** ជាគុ. (អាចក្លាយមកជាពាល ប្រែថា តាប
សាហាវ) (ពាទ្យម្រឹគ ឬ វាទ្យម្រឹគ) ។

- **ពាល** ជាគុ. ប្រែថា ទន់, ដែលនៅក្មេង, ល្ងង់
ខ្លៅ, តាប, សាហាវ, អាក្រក់ (ព្រះអាទិត្យ
ពាល គឺដែលទើបរះមានពន្លឺនៅស្រទន់,ក្មេង
កំពុងពាល) ។

២- គឺ.-

- **គឺ** ជាគុ. ប្រែថាឥតសំដី (មនុស្សគឺ) ។

- **គឺ** ជានាម គឺឈ្មោះឈើ ផ្លែវាមានសរសៃជាប៉ុយ
សំឡី (សំឡីគឺ) ។

- **គុន** ជាកិ. គឺធ្វើឲ្យជាគំនរ ។

ចំណាំ : ពាក្យផ្សំទឹងគ្នាមុខ ដែលមិនសរសេរជា
មួយគ្នាគឺមាន:

- គគាប, គគាត, គគីរ, គគឹក, គគឹត, គគុក, គគុកគគាក់, គគុល, គគុះ, គគើម, គគ្រក់, គគ្រង់, គគ្រាក់, គគ្រាត, គគ្រឹងគគ្រាំង, គគ្រិប, គគ្រិះ, គគ្រឹតគគ្រាត, គគ្រើរ, គគ្រើស, គគ្រូស, គគ្រឹក, គគ្រឹកគគ្រេង, គគ្រឹម, គគ្រឹត, គគ្រូក, គគ្រូម, គគ្រូយ, គគ្រូក, គគ្រូប, គគ្រើម, គគ្រេង, គគ្រេងគគ្រាំ, គគ្រោក, គគ្រាំ, គគ្រាំង, គយរ, គយារ, គយឹក, គយូស, គយ្យរ, គយ្ងន ។

៣- ភណ្ឌា :

- **តណ្ឌា** ឬ **តណ្ឌា**: ជានាម ប្រែថា ទ្រព្យ, របស់ដើមទុន, ឥវ៉ាន់, ប្រដាប់ (បុពណាកណ្ឌ) ។

- **តណ្ឌ** ឬ **តាណ់** ជាកិ. គឺជ្រួស, ប្រឡំ, ខុសទំនង (កាន់តនិត, កាន់ផ្លូវ) ។

៤- លាង :

- **ឡាង** ជាកិ. គឺជម្រុះ, សម្អាត (លាងដៃ) ។
- **ឡៀង** ជាកិ. គឺបិញ្ចឹម, ចិញ្ចឹមរក្សា (ឡៀងជីវិត, ស៊ីឡៀង, ឡៀងអារក្ស) ។
- **ឡៀងតា** ជានាម គឺឈ្មោះសត្វចតុប្បាទប្រភេទមួយប្រភេទ រូបពងស្រដៀងនឹងសត្វកែះ តែមាត្រតូចជាង ។

x

x x

ទី១៣- កម្មវិធីប្រទេសសុខសាន្ត

ព្រឹត្តិការណ៍ថ្មីៗនៃពិភពលោក បេះតែឡើងបន្ត

បន្ទាប់គ្នា ដោយហេតុអកនិយោជ្ជាយ ដែលជាមគ្គទេសក៍
រវាងប្រទេសពាំងឡាយមានទស្សនៈទំនងខុសគ្នាពីស្រេចគ្នា ។
អ្នកខ្លះប្រាថ្នាដឹកនាំប្រទេសជាតិទៅតាមមាគ៌ានិយោជ្ជាយបែប
នេះ ខ្លះទៀតចង់ទៅតាមគន្លងនោះវិញ ។ យោបល់មិនស្រប

គ្មានេះ នាំឲ្យកើតមានវិបត្តិនិងបដិបក្សរវាងគ្នាឯង ។

ក្នុងទស្សវត្សរ៍បច្ចុប្បន្ននេះ ប្រទេសខ្លះនៅអាស៊ីបូព៌ាគេ
អាចនិយាយបានថាកំពុងតែជួបនឹងអស្ថិរភាព ទាក់ទងសព្វ
ពេញលើផ្នែកប្រទេស មានតែប្រទេសកម្ពុជាមួយគ្រឹះមួយ
ប៉ុណ្ណោះទេដែលបានទទួលនូវសុខសន្តិភាព សម្បូរណ៍សប្បាយ
តែម្នាក់ឯង ។ ក្នុងឱកាសដែលស្មារតាំក្លឹង គ្រាប់បែកកំពុង
ផ្ទុះនៅក្នុងប្រទេសជិតខាងយើង គេឃើញមានបម្រែងរាំរែក
សំណើចក្អាកក្អាយ ក្នុងការប្រកបរបរអំពៃន្ទ្រយ៍នៃពលរដ្ឋខ្មែរ
ជនបរទេសខ្លះ ដែលធ្លាប់តែផ្សឹសំដីសប្បុរសរបស់ប្រទេស
ដែលជាអម្ចាស់កម្ពុជា កាលបើបានជាន់ដីខ្មែរពេលណា ក៏
ស្រាប់តែភ្លាក់អាត្មាស្រឡាំងកាំង ដោយឃើញប្រទេសខ្មែរ
សម្បូរណ៍សប្បាយ មានវឌ្ឍនភាពគ្រប់មជ្ឈដ្ឋាន ។ ប៉ុន្តែ
ច្បាស់ដែលកើតពីការផ្ទុះត្រៀកនៃប្រទេសអភ័ព្វទាំងនោះ ក៏ត្រូវ
រលាយសូន្យទៅដូចអំបិលត្រូវទឹក ។ អ្នកទេសចរ អ្នកយក
ព័ត៌មាន អ្នកពិនិត្យការណ៍គ្រប់សញ្ជាតិ គ្រប់ពណ៌និយោបាយ

ដែលមកកាន់ប្រទេសខ្មែរ តែងបានទទួលកត្តិភាព សមានចិត្ត
និងការឧបត្ថម្ភសើមខ្លាំពីអតីតកាន់អំណាចខ្មែរ ។
ស្មុខសន្តិភាព រួមនភាព និងភក្តីសព្វជាអាទិ នៃប្រ
ទេសខ្មែរនេះ ពិតជាលទ្ធផលដែលបានហូរមកតាមព្រះរាជ
នយោបាយដ៏ក្លៀវក្លានៃព្រះប្រមុខរដ្ឋខ្មែរជាប្រាកដ ។ ព្រះអង្គ
ពុំមែនយកព្រះទ័យទុកដាក់តែនឹងសេចក្តីសុខសាន្ត និងសុខុ-
មាលភាពនៃប្រជាពលរដ្ឋព្រះអង្គតែប៉ុណ្ណោះទេ គឺរហូតដល់
សន្តិភាពសកលលោកទៀតផង មានកុសតាងនាសន្តិសិទ្ធនៅ
ក្រុងហ្សឺណែវនិងអង្គការសហប្រជាជាតិជាសក្ខីភាពស្រាប់ ។

ឈរជើង - វេរឿង

សំឆ្លៃ

១ - ចូរពន្យល់ពាក្យ ព្រត្តិការណ, ឧត្តមគត,
បដិបក្ស,ប្តូរនិម្មិយ,សមានចិត្ត,សក្ខីភាព។

២- ចូរស្រង់ឧទាហរណ៍ពីរបីឃ្លា និងអត្ថន័យ
ខ្លះ ដែលមាននៅក្នុងអត្ថបទនេះ រួចហើយ

បញ្ហាគំពីរបៀបប្រើកិរិយានេះផង ។

៣- ចូរអធិស្ឋានដល់ព្រះពុទ្ធ ដើម្បីឲ្យបានសម្រេចនូវ
ទាំងធម្មជាយ៉ាងណាផង ។

៤- តើចំពោះព្រះរាជសកម្មភាព យ៉ាងណា
ខ្លះ ដែលប្រជាពលរដ្ឋយើងបានថ្វាយនាម
ដល់សម្តេចនុថា ជាព្រះបិតាសន្តិសុខ
ជាតិ និងសកលលោកផង ? ។

មធ្យមសិក្សាប័ត្រ

លើកទី១ ថ្ងៃ ១៤-៥-៦៤

កំណត់ចំណាំ

១- ពន្យល់ពាក្យ.-

- **ព្រឹត្តិការណ៍** (ន.) ហេតុ ឬដំណើរដែលប្រ
ព្រឹត្តទៅតាមប្រក្រតី (l'événement) ។
- **ឧត្តមគតិ** (ន.) គតិឧត្តម ឬដំណើរកើតល្អ, ចិត្ត
គំនិតខ្ពង់ខ្ពស់, អធ្យាស្រ័យដែលដុះចេញមក

ដើម្បីរំនេះរកសេចក្តីសុខ-ចម្រើន, ប្តូរគោលបំណង
ចង់ឲ្យបានល្អប្រសើរ (l'idéal) ។

- **បដិបក្ស** (គុ.) ដែលផ្ទុយនឹង, ដែលជំទាស់
មិនស្រុបជាមួយ (ennemi, opposant) ។

- **បុរេនិដ្ឋច័យ** (ស.ន.) ការវិនិច្ឆ័យដោយគ្មាន
ពិចារណា, ដោយឆឹតឆឹលំ, ការវិនិច្ឆ័យ
ដោយស្មានរំពើរពាយ ។

- **សមាធចិត្ត** (ស.ន.) ចិត្តស្មោះស្មើ, ចិត្តដែល
មានសភាពទន់រកគ្នា ដោយសេចក្តីស្រ-
ឡាញ់ ។

- **សក្ខីភាព** (ន) ដំណើរជាសាក្សី (le témoignage, la preuve)

២. **អក្ខរាទិវុទ្ធ** .-

- **បដិបក្ស** (អាចសរសេរជា បដិបក្ខ ឬ ប្រតិបក្ស
ដូចខ្លះបាន) ។

- **ទេសកាល:** (ទេសកាល: សរសេរ យុត្តល

ពាន្ធុ តែគ្រោយ កាល: ខ្ញ ។ ដើម កាល-
ទ្វែស: កំចាន) ។

- **អារគ្គយ៏** (សរសេរ អា គ្គ ន ធ យ៏) ។
- **ជុរិន្ទក្ស** (អាចសរសេរ ទ្វ ពិ ក្ក ដូចខាងក្រោម កំចាន ។
  គេសរសេរ ន ធ ស្រ: ិ) ។
- **អព្យាក្រឹត** (សរសេរ ក្រ ស្រ: ឹ ន ធ ត) ។
- **ចម្រៀង** (សរសេរតម្រួត មកពី ប្រៀង ។
  ពីមុនអាចសរសេរ បំរៀង ចាន) ។
- **អចិន្ត្រៃយ៏** (សរសេរ អ បិន្ត្រៃ ន ធ យ៏) ។
- **ឬទ្ធ** (អានថា ប៊ុ ទ្ធ) ។
- **អភ័ព្វ** (អាចសរសេរ អភ្ញ ឬ អភ័ព្ញ ដូចខាងក្រោម
  ចាន) ។
- **ឧបត្ថម្ភ** (កុំប្រឡំនឹង ឧបត្ថម្ភក ជានាម ប្រែថា
  អ្នកទំនុកបម្រុង) ។

៣- **សទិសសព្ទ** នៃពាក្យ :

១- លិប .-

- **លិច** ជាកិ. ប្រែថា លិបបុះចុតទៅ, ចូលកប់ ចុតទៅក្នុងទឹក (ទូកលិច, ព្រះអាទិត្យលិច, លិចខ្យល់) ។

- **លិច** ជានាមគឺឈ្មោះទិសដែលព្រះអាទិត្យអស្តង្គត (ទិសខាងលិច, នៅឯលិច) ។

- **លេច** ជាកិ. គឺចេញពីទីកំបាំង (ស្រាប់តែឃើញលេចចេញពីក្នុងព្រៃមក); ជ្រាបហូរចូល (ទឹកលេចពីក្តីស្រែ); លៀនចេញ (ត្រាប់ឈើដុះលេចពន្លកពីក្នុងដី); ផ្ទាយ, ផ្សាយចេញ (លេចដំណឹង) ។

- **លេច** ជាគុ. ប្រែថា ដែលមិនគត់ (ក្អមលេច, ផ្ទះលេច); មាត់រអិល (មាត់លេច) ។

- **លេច** ជានាម គឺឈ្មោះដំរៅកើតនៅបាទដើង

(ដំណូលលេច) ។

២- សូន្យ .-

- **សូន្យ** ជាគុ. ប្រែថា ទទេ, រលែត, រលោះទទេ

(សូន្យឈឹង, សូន្យរលោះ, សូន្យសុង)

- **សូន្យ** ជានាម គឺការៈទទេ, ពន្លូកស្បែល, និគ្គហិត

(សូន្យ ១, សូន្យ ២)

- **សូន** ជាក. គប្រមូលអ្វីដែលមានសាចទន្ទ្រាយ

ស្បែកជាដុំ, ជាគ្រាប់, ជារូប, (សូនគុលិ-

កា, សូនរូប, សូនម្សៅ) ។

x

x x

ទី១៤- យុវជនខ្មែរ

យុវជនខ្មែរតាំងអស់ គោះប្រុសក្តី ស្រីក្តី ជាកម្លាំងមួយ
ផ្នែកយ៉ាងសំខាន់ក្នុងការបម្រើប្រទេសជាតិមាតុភូមិ ។ យុ-
វជនយើងត្រូវតាំងសតិសម្បញ្ញៈឲ្យភ្ញាក់រលឹកជានិច្ច ព្រមទាំង

មានសតិអារម្មណ៍ខ្ជាប់ខ្ជួនប្រសើរឧត្តមជាងពួកតែត្រូវមាន
សន្ដានចិត្តចេះសង្កោច មានអធ្យាស្រ័យចេះទន់ហន់ចេះ
សាមគ្គីជិតស្និទ្ធស្រឡាញ់រាប់អានរកមិត្តភក្តី មិនប្រទូសប្តូរ-
មាឋមើលងាយយុវជនដទៃ មិនសេពគប់ស្និទ្ធស្នាលជាមួយ
ទីឥមនុស្សព្រាលអបលក្ខណ៍ និងមិនប្រព្រឹត្តលេងល្បែងពាលា
ដែលនាំមកទុរាគាសនៃពីរដល់ខ្លួនឡើយ ។

នៅតាមជនបទស្រែចំការ ឬនៅតាមពេលចប្រកួនសូកហ-
កម្ម យុវជនជាកសិករ ឬ កម្មករត្រូវតែបញ្ចេញសមត្ថភាពឲ្យ
អស់ពីចិត្ត ប្រឹងប្រែងរកសរវៃប្រកបការងារដែលជាគាតព្វ-
កិច្ចរបស់ខ្លួន មិនស្អប់ស្អើរ ឬតូញតែរ ដោយនិតទំបង្អើត
ផលិតផលគ្រប់ដំណាក ឲ្យបានសម្បូណ៌ហូរហៀរប្រើនជាង-
នេកប្បការ ដើម្បីសាងសេដ្ឋកិច្ចជាតិឲ្យបានចំរើនលូតលាស់
ធាប់រហ័សទាន់សម័យនិយម ។

នៅតាមអាគារសិក្សា យុវជនអ្នកសិក្សាកាមត្រូវតែព្យា-
យាមរៀនសូត្រសព្វសាស្ត្រវិជ្ជាតាមក្រិត្យក្រម ដើម្បីបណ្តុះ

និស្ស័យ ភាសនារបស់ខ្លួនឲ្យទៅជាអ្នកចេះដឹងឈ្វេងយល់ ប្តូជា
អ្នកប្រាជ្ញបណ្ឌិតយ៉ាងចំណានក្នុងពេលអនាគត ។

នៅក្នុងគ្រាអាសន្នដែលមានខ្មាំងសត្រូវបួលលុកលុយ
ទន្ទ្រានប្រទេសជាតិ យុវជនទាំងអស់ត្រូវតែធ្វើពលីកម្មចេញ
តយុទ្ធពុះពារយ៉ាងអង់អាចជាមួយបក្ខពួកត្រូវលុះត្រាតែដណ្តើម
បានជោគជ័យជាអវសាន ។

យុវជនខ្មែរមិនត្រូវបណ្តែតបណ្តាយ ធ្វើឲ្យជីវិតដ៏មាន
តម្លៃរបស់ខ្លួនដែលត្រូវបានទៅបុប្ផាកំពុងរីកស្គុសស្គាយផ្សព្វ
ផ្សាយក្លិនគន្ធពិដោរនោះឲ្យស្រោពោនវិញបានឡើយ ។ ដោយ
សារកម្លាំងដ៏រឹងប៉ឹងយ៉ាងប្រត្យក្សនៃយុវជននេះ ប្រទេសកម្ពុជា
នឹងបានទទួលអាវុធម៌ ព្រមទាំងវឌ្ឍនធម៌ជាតិវប្បធម៌ សាលយូរ
អង្វែង ដូចមហាប្រទេសស្មើរលើយនានាក្នុងសកលលោក ។

សំណួរ

១- ចូរពន្យល់ពាក្យ *សតិសម្បជញ្ញៈ, សមត្ថ*
ភាព, កាតព្វកិច្ច, ពលីកម្ម, ប្រត្យក្ស ។

២- ចូរអធិប្បាយសព្ទ នៃពាក្យ "ការ" ។

៣- យុទ្ធជនម្នាក់ៗ មានការណ៍យកចិត្តយ៉ាងណា?

មធ្យមសិក្សាបត្រ

(លើកទី ២ ថ្ងៃ ៦-៨-៦៤)

កំណត់ចំណាំ

១- ពន្យល់ពាក្យ :

- សតិសម្បជញ្ញៈ ស្មារតីនិងសេចក្តីដឹងខ្លួន ។
- សមត្ថភាព ភាពនៃសេចក្តីអាចហាន, សេចក្តីមោះមុត ។
- ភារតព្វកិច្ច ការណីយកិច្ច, កិច្ចដែលត្រូវធ្វើ, ការងារដែលត្រូវតែធ្វើ ។
- ពលិកម្ម ការបូជា, ការសង្គ្រោះ ។
- ប្រុងប្រៀប (ប្ដូ ប្រែបក្ស) ដែលជាក់, ច្បាស់, មែន. ពិត ។

២- អក្ខរាវិរុទ្ធ .-

- **កម្លាំង** (សរសេរតម្រួត ព្រោះមកពី កាំង ។ ពី មុនអាចសរសេរ កំឡាង ជាន) ។
- **បង្រៀ** (សរសេរតម្រួត ព្រោះមកពី ប្រើ ។ ពី មុនអាចសរសេរ ប្រំរៀ ជាន) ។
- **ដិច្ច** (សរសេរ ជិ និង ច្ច) ។
- **សន្តាន, សន្តោស** (សរសេរប្រកបនឹង ជ ដេង ព) ។
- **ម៉ត់ម៉ង** (អាចសរសេរ ម៉ាត់ហ្មង ម្ហត់ហ្មង ជាន)។
- **ស្ម័គ្រស្មោគម** (ស្ម័គ្រ សរសេរ ស្ម័ និង គ្រ ស្មោគម សរសេរ សា - គ និង ម) ។
- **ឆោសនៃពន៍** (ពៃព៍ សរសេរ ពៃ និង ន៍) ។
- **ឧទាសនៃត** (ឧទាស សរសេរ និង ស្រៈ -ា ។ នៃត សរសេរ នៃ ស្រៈ ៃ -) ។
- **ស្ទឹរ** (មាន រ ចុង) ។

- វ័ក្ស្នែរ (មាន រ៉ ចុង) ។
- ដំព្ងក (អាចសរសេរ ប៉ំព្ងក ក៏បាន) ។
- ហ្វរហ្វៀរ (ស្មុគ្មតែមាន រ៉ ចុង) ។
- អរាគារ (សរសេរ អា និង គារ (មាន រ ចុង) ។ មិនមែន អគារ ទេ ។
- ឈ្លោសង៉ែង (សរសេរ ឈ្លោ និង ស ។ ង៉ែ សរសេរស្រះ ង៉ែ-) ។
- ញុះញោរ (សរសេរ រ៉ ចុង ។ ស្រះ -ា) ។
- ជ្រង្វ (សរសេរ ជ្រៀ និង ង្វ) ។

៣- សទិសសព្ទ នៃពាក្យ :

១- សូត្រ .-

- **សូត្រ** ជានាម ប្រែថា ចេស, ខ្សែធ្នារ, សរសៃធ្នារល្អិត (ស្រាវសូត្រ, សំពត់សូត្រ) ។
- **សូត្រ** ជានាម គឺព្ទវចន:ចំណែកមួយ (ព្រះសូត្រ)-គោលវេបស់ការសិក្សាសម្រាប់ទេន្ទញ

ទ្រៃចាំ (គោលសូត្រ, មេសូត្រ) ។

- **សូត្រ** ជាកិ. ថាតាមរបៀបពាក្យដែលទន្ទេញចាំ មាត់ (សូត្រធម៌, សូត្រអាគម) ។

- **សូត** ជានាម ប្រែថា សារថី, អ្នកបរថ, សំដី សម្តែងអំណរ, ការថ្លែងអំណរ ។

- **សូធ ឬ សូធ**: ជានាម ប្រែថា អ្នកចំអិនអាហារ, អ្នកជាំស្ងួ (សូធកម្ម, សូធវិជ្ជ) ។

- **សូទ្រ ឬ សូទ្រ**: ជានាម គឺមនុស្សកើតក្នុងវណ្ណៈ ទី ៤, អ្នកងារ (ពួកសូទ្រ) ។

២- ឬ .-

- **ឬ** ជាគុ. ប្រែថា ធាប់, រហ័ស, ភ្លាម, ធាប់ភ្លាម (ធាប់ឬ, ទៅឬៗ) - ឈ្លាស, ស្ទាត់ប្រាកដ, ជំនាញ, ប៉ុន (ប្រាជ្ញាឬ, ត្រេចៀកឬ, វាងឬ) ។

- **វ័យ ឬ វ័យ**: ជានាម ប្រែថា អាយុ, កំណត់អាយុ (វ័យក្មេង, បឋមវ័យ) ។

๓_ ពារ .-

- **ពារ** ជាកិ. ប្រែថាប៉ះលើ (ពារបង) ។

- **ពារ** ជានាម ប្រែថា ថ្ម (ពារពុធ) ។

- **ពេវ៉ែន** ជានាម ប្រែថា ចំណងចិត្តជាសត្រូវ (ចង

ពៀរ, ពៀរវេរ) ។

៤_ ខាន់ .-

- **ខាន់** (មកពីពាក្យ **ខ័ន** ឬ **ខ័ណ្ឌ**) ជានាម ប្រែថា

គ្រឿងសស្ត្រាមួយប្រភេទ ផ្នែមានមុខតាំង ២

ខាង (ព្រះខ័ន ឬ ព្រះខាន់) ។

- **ខណ្ឌា** ជានាម ប្រែថា សង្កាត់, ប៉ែក, កំណាត់,

ប៉ែកសាណាំខ្ចែ (ខណ្ឌភ្នំពេញ) ។ សព្វថ្ងៃ

គេប្រើពាក្យ ស្រុក ជាដំនួសខណ្ឌវិញ ។

- **ខណ្ឌា** ជានាម ប្រែថា កម្រិត, បម្រាមផ្តាច់មិនឲ្យ

ធ្វើ (ទៅបន ឥតមានខណ្ឌទេ) ។

- ខជ្ជ ជានាម ប្រែថា ក, ដើម, គំនរ, ពួក, កង, កំណាត់ (ខន្ធ៥, វំលត់ខន្ធ) ។

សរេត .-

ក

๑- ពាក្យសរសេរមាន ខាត់ ពីមុខ គឺ :

- ខាន់ទៅ, ខាន់ដាប, ខាន់លឿង, ខាន់ស្វា, ខាន់ស្វាក់ ។

๒- ពាក្យសរសេរមាន ខ្ញុំ ពីមុខ គឺ :

- ខ្ញុំណាខាប់, ខ្ញុំណាសញ្ញា, ខ្ញុំណាស្ពរ, ខ្ញុំណាស៊ីមា ។

x

x x

ទី១៥- ប្រទីបអក្សរសាស្ត្រ

អក្សរសាស្ត្រជាអរូបនាមមួយផ្នែកដែលមានន័យលក្ខណៈ ធំទូលំទូលាយសម្រាប់បណ្តុះនូវនិស្ស័យវប្បធម៌ នៅក្នុងខន្ធ សន្ទានៃសត្តនិករទូទៅ ។

អក្សរសាស្ត្រជាសាខាមួយផ្នែកក្នុងរឿងវប្បធម៌ ដែលជា
សតាពការណ៍ប្រឹងផ្ដល់នូវអារម្មធម៌និងវឌ្ឍនធម៌ដល់មនុស្សនិ-
ករទូទាំងពិភពសាកល ។ អរូបនាមនេះ មានបុព្វានុភាពដ៏ស្កុ
សិទ្ធិ និងជាអត្ថបរមាក្នុងការសំគាល់នូវការរីឌ្ឍន៍នៃមនុស្ស
ម្នាក់ៗ ។ ជនណាប្រកបដោយអក្សរសាស្ត្រនៅក្នុងខ្លួន ពោល
គឺជនណាប្រកបដោយចំណេះវិជ្ជាផ្សេងៗ គេតែងសន្មតថាជន
នោះមានទស្សនៈភ្លឺស្វាង ហើយទទួលនូវសេចក្ដីថ្លៃថ្នូរជាមិន
ខាន ឲ្យតែចំណេះវិជ្ជានោះឈរនៅលើគោលល្អក្ខណៈល្អ
ព្រោះថា "ចំណេះវិជ្ជានាំឲ្យមានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិ
ផ្ដល់នូវសេចក្ដីសុខចំរើន សេចក្ដីសុខចំរើននាំឲ្យមនុស្សទទួល
នូវសេចក្ដីថ្លៃថ្នូរ" ។

ទន្ទឹមនឹងនេះ យើងឃើញថា អក្សរសាស្ត្រជាទំនុំ
អម្រឹតដ៏មានមហិទ្ធិឫទ្ធិជាមហស្ចារ្យម្យ៉ាង អាចប្រោះព្រំពង្ស
មនុស្សឲ្យស្ទុះរីឆ្ពោះទៅរកសេចក្ដីចំរើន និងសេចក្ដីថ្លៃថ្នូរបាន ។
គេតែងសំគាល់វឌ្ឍនភាពជាមួយៗ ស្របទៅតាមដំណើរវប្ប-

ធម៌ឬអក្សរសាស្ត្រនៃប្រទេសនោះ ព្រោះជាវត្ថុនៃការគ្រប់
រៃយ៉ាដ្ឋិតទៅតាមទម្រង់វប្បធម៌ ឬដូចប្រជាភាសិតជាសក្ខីភាព
ថា "អក្សរលត់ ជាតិការលាយ" យ៉ាងនោះដែរ ។

ម្យ៉ាងទៀត តាមដំណើរខាងលើនេះ សម្តេចព្រះអគ្គ
មគុរុសក៏ ដែលជាព្រះបិតាវប្បធម៌ជាតិបាន ឈ្វេងយល់នូវ
ចាត់វិធានការថ្មី គឺអក្ខរបន្ទាយកម្ម ដើម្បីបំបាត់អនក្ខរភាពជូន
សព៌ាស្ថារតីប្រជាពលករមួយចំនួន ដែលធ្លឹតធ្លង់ទៅ
ទៀត ។

ព្រះពុទ្ធវិធានការថ្មីៗ នេះ ត្រូវបានទទួលការគាំទ្រយ៉ាង
សកម្មនិងពេញទំហឹងពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋខ្មែរ ។

សំណួរ

១- ពន្យល់ពាក្យ ខន្ធសន្តាន, វប្បធម៌, សត្តនិ-
ការ, សក្ខីភាព, អក្ខរបន្ទាយកម្ម, អនក្ខរភាព ។

២- ដូចម្តេចដែលហៅថាឆាងនាង? ចូរតែ
នាមនាមពាំងនោះដោយខ្លួនឯង ឧទាហរណ៍

នៅក្នុងអត្ថបទនេះ ។

៣- ចូរសម្ដែងពាក្យ ក្នុង ឃ : "អក្សរសិល្ប៍ជាតិកំរោយ" ។

មធ្យមសិក្សាបឋម

លើកទី ១ ថ្ងៃ ៣ -៦. ៦៥

កំណត់ចំណាំ

១. ពន្យល់ពាក្យ .-

- **ខន្ធសន្តាន** កំណើតពូជពង្ស, ប្រជុំទឹកចិត្ត ។
- **វប្បធម៌** ការផ្សាភណ្តុះវិជ្ជា និងប្រកាជ្ញាស្មារតីឲ្យបានចំរើនលូតលាស់ដោយវិទ្យាសាស្ត្រ ឬដោយសិល្បៈផ្សេងៗជាដើម (la culture) ។
- **សត្តឆកិរ** ឈ្មោកសត្វទាំងពួង (គម្ពុជសត្វនៅលើលោកនេះ) ។
- **សក្ខីភាព** ដំណើរជាសាក្សី (la preuve) ។
- **អក្ខរូបនីយកម្ម** ដំណើរ ឬការរៀបចំបង្រៀន

អក្ខរ ឬអក្សរចំរោះប្រជាពលរដ្ឋ alphabétisation ។

- អនក្ខរភាព ភាពមិនចេះអក្សរ analphabète ។

២- អត្ថរាភិធេ .-

- ការពិពណ៌នា (វិរិត្តរ៍ សរសេរ ឲ្យ ខាងចុង)។

- ដែលជួរ (ប្រុ មាន រ ចុង) ។

- ជិញ្ជូ (សរសេរ ទ្វិ នឹង ញ្ជូ) ។

- ត្រែចារះត្រែ (សរសេរ ត្រែ្រ នឹង ស្រៈ ុ , ត្រែ

សរសេរ ត្រែ នឹងស្រៈ ុ) ។

- ឈ្នួច (កុំប្រែឡំនឹង ឆ្នែង) ។

៣- សទិសសព្ទ នៃពាក្យ :

១- ត្រែះ :

- ត្រែចារះ ជាកិ. ប្រែថា ចាបគ្រាប់ពូជល្អិតៗ ដើម្បី

ឲ្យដុះលូតលាស់ឡើង (ត្រែះតែស្ពៃ, ត្រែះ

ស្រូវ) ។

- ទ្រោះ ជាគុ. ប្រែថា ហេតុ ដូច្នេះ (រឿង ពុំបេះ ទ្រោះខ្លី, ទ្រោះតែ) ។

- ទ្រោះ ជាគុ. ប្រែថា ស្ងួត (គោទ្រោះ គឺគោស្ងួត) ។

- ទ្រួស ជាកិ. គឺបញ្ចេញទឹក ឬ ទឹកមាត់ពីក្នុងមាត់ឲ្យខ្ចាយព្រោង ដោយកម្លាំងខ្យល់ (ទ្រួសទឹក, ពស់ទ្រួសពិស) ។

x

x x

ទី១៦- ឈរមុខទៅរកវឌ្ឍនភាព

ក្នុងអតីតកាល មានភូមិយើងជាប់ជាន់ជាមហាអំណាចមួយក្នុងភូមិភាគសុវណ្ណភូមិ ដូចមានបុពណ្ណវត្ត សិលាច្រឹងសាខែលេសេសសល់ពត៌ាយនៅលើភូមិភាគនេះសព្វថ្ងៃ ជាសក្ខីភាពស្រាប់ ។

ប៉ុន្តែដោយហេតុតែមានសេចក្តីប្រមាទធ្ងន់ និងមាន

សាមគ្គីគេចេរវៀងគ្នាឯងជាញឹកញយ ជាទុក្ខាសន្សែរដ្ឋជិតខាង
ខ្លះ ដែលមានមហិច្ឆតាលោភលន់ចូលមកតាធ្វើទុក្ខនាំបំបះបំ
បោរពលរដ្ឋឲ្យក្លាតសតិសម្បជញ្ញៈជាក់កងមិច្ឆាមគ្គ ។ ឯពលា
ទុកាពនៃរដ្ឋខ្មែរកំប្រែជាទន់ខ្សោយ ហើយនៅទីបំផុតកំលង់
ខ្លួនកងឋានសភាពនៃសាសន៍ស្បែកសខ្មៅ ។ តាំងពីពេលយ៉ាំ
នោះមក អាយធម៌និងវប្បធម៌ជាតិកំពុងអន់ស្រោយ ។ ឯអាយ
ធម៌និងវប្បធម៌បរទេសត្រូវបានគេសាបព្រោះបណ្តុះឡើង ។
កងឆ្នាំ ១៩៥៣ សតវត្សរ៍ថ្មីបានចាប់ផ្តើមឡើង ។ ស្មារតី
ក្លាក់រលំកំពុងសន្ធឹសីភាពនិងឯកភាជ្ជជាតិ បានផុសលេច
ឡើងគ្រប់មជ្ឈដ្ឋាន ។ ក្រោមព្រះកិច្ចដឹកនាំប្រយុទ្ធពាមការ
នៃសម្តេចព្រះ **ឧវរាគ្គម សីហាឧភ័ន្ត** មាតុភូមិយើងក៏បាន
ហាន:ជាកុដិស្បៃភាពឡើងវិញ ។ តាំងពីពេលនោះមក ខ្មែរទូ
ទៅគ្រប់ហាន:បានខិតខំស្តារបនាប្រទេសជាតិ ដោយឥតសំចៃ
កម្លាំងឡើយ ។ កងដំណើរទៅមុខនេះ ពលរដ្ឋគ្រប់រូបរួមដុំ
វិញអង្គសម្តេចឯ បានពុះពារដោយក្លាហាន ន្ទូវឧបសគ្គបង្អាក់

ដំណើរវិវឌ្ឍន៍នៃមាតុភូមិយើង ។ សម័ទំនើបៗដែលជាលក្ខណៈ
ចាំបាច់នៃឯកភាពជាតិក៏បានលេចផុសព្រោងព្រាតទៀត លើ
ផ្ទៃអាណាចក្រគម្ពុជាយើងបើដូចជាគេជបដោយទិព្វមន្ត ។

សង្ខេប

១. ចូរពន្យល់ពាក្យ *សក្តិភាព, សាមគ្គី, មហិច្ឆ-*
តា, វិទ្ធង្សនា, មិច្ឆាមគ្គ, កុដិសង្ឃភាព ។

២- ចូររកពាក្យផ្ទួយនឹងពាក្យ *សាមគ្គីភេទ-*
អាយធម - កុដសង្ឃភាព ។

៣- ចូររកវេវចនសព្ទ *នឹងពាក្យ : "ព្រោះ"*
សាបព្រោះ ហើយពន្យល់ន័យនៃពាក្យ
នោះផង ។

៤. ពាក្យបែបណាហៅថា *នាមនាម ? សព្ទ*
បែបណាហៅថាសមាសនាម ? ចូររកឧទា-
ហរណ៍ក្នុងអត្ថបទឲ្យបានច្រើន យ៉ាងតិច ។

មធ្យមសិក្សាបច្ចុប្បន្ន
លើកទី១ ថ្ងៃ ១៦-៥-៦៦

កំណត់ចំណាំ

๑- ពន្យល់ពាក្យ .-

-- **សក្ខីភាព** ដំណើរជាសាក្សី (le témoignage, la preuve) ។

- **សាមគ្គី** សេចក្តីព្រមព្រៀង , ដំណើរស្មុះគ្នា (la solidarité) ។

- **មហិច្ឆតា** សេចក្តីប្រាថ្នាធំ, ការចង់បានច្រើន, សេចក្តីលោភលន (l'ambition) ។

- **ទិដ្ឋប្បធារ** (ម្ភរិទ្ធិសព្ទ) ការកំចាត់បង់, ការបំផ្លិចបំផ្លាញ, អំពើបំបះបំបោរដើម្បីរំលំរំលើងរបបគ្រប់គ្រងរដ្ឋ (la subversion) ។

- **មិច្ឆាមគ្គ** ផ្លូវខុស, ផ្លូវដែលមិនពិត (le faux chemin) ។

- **ភូតិសព្ទភាព** (ម្ភភូធិសព្ទ្ធ) ភាពជាអ្នកជា, ដំណើរឥតជំពាក់បំណុលគេ (l'innocence) ។

២- អក្ខរាទិរុទ្ធ

- អនិយ្យេធមិ (អាចសារេសារជា អារ្យធម៌ ក្នុ) ។
- សតតវត្ត (អាចសារេសារ សតតវ័ត្ត៌ ដូរច្នេះក្នុ ន)។
- ឆុស (សារេសារ ឆ្មុំ នឹង ស) ។
- ឆាយឆាវ (ទ្វារ មានរន្ធចុង) ។
- ឋាន: (សារេសារ ឋា) នឹង ជ) ។
- ឋប (សារេសារ ជ នឹង ប ឥត បន្ត្រក់ទេ) ។

៣- សន្ធិសមាសព្ទ នៃពាក្យ :

១- សេស :

- សេស ជាគុ. ប្រែថា ដែលសល់, ដែលឥតគូ (បរិសេស, លេខសេស) ។
- សេស ជានាម ប្រែថា សំណល់, របស់ជាដែលអស់រលីងឥតមានសេស) ។
- សេស ជាកិ. ប្រែថា ដែលសល់ពីគេ, ក៏មានសល់ (អាហារសេសសល់, សេសមួយ) ។

- **ឧស្ស** ជានាម គឺបស្ចុស្សតូចតុប្បាទ (សត្វឧស្ស, ឧស្សទេស) ។

- **ឧស្ស** ជានាម គឺឈ្មោះក្តាមសម្រួច (ក្តាមឧស្ស) ។

២- សាសន៍ :

- **សាសនិ** ជានាម (ពុទ្ធសាសន៍, សាសន៍ខ្មែរ) ។

- **សារ្ស្ត** ជានាម ប្រែថា គម្ពីរ, ច្បាប់, ក្បួន, តម្រា, វិជ្ជា (ប្រវត្តិសាស្ត្រ, វិទ្យាសាស្ត្រ) ។

- **សារ្ស្ត** ជានាម ពាក្យក្លាយមកពី សស្ត្រ សស្ត្រា (មុខសាស្ត្រ) ។

- **ស:** ជាកិ. គឺជាដំបៅ (ស:ដំបៅ, ស:ស្នាយ) ។

៣- ស :

- **ស** ជា គុ. គឺដែលមានសម្បុរដូចសំឡីកប្បាស (ពណ៌ិស, សំពត់ស) ។

- **ស** ជា កិ. គឺចាក់ប្ដុះព្រោះដោយស្នូ (ស្រូ) ។

- **ស** ជា កិ. គឺសង្កេតរកគ្រោះ។ ដោយសម្លេង។ ឬ
ឃើញ (ស រកឲ្យឃើញ) ។

- **សរ** ជានាម ប្រែថាព្រួញ, កាំ, កាំភ្លើង (ស្មៅចង្អឹ
សរ, ត្រែវសរ, កូនសរ) ។

- **សរ** ជា កិ. គឺរឭក, រឭកឃើញ, នឹកឃើញ,
សាដឹងឡើងវិញ (សរជាតិ, សរញ្ញាណ) ។

ចំណាំ.-

ពាក្យសរសេរមាន ស័រ នៅពម្មុខ គ:

- សរណៈ, សរទៈ, សរទកាល, សរពង្គ, សរពើ,
សរពេជ្ឈ, សរកណ្ឌ, សរសន់, សរស៊ើ, សរសរ, សរសៃ។

២- ជប :

- **ជប** ជា កិ. ប្រែថា ខ្សឹប, ស្ងាធ្យាយខ្សឹប។, សូត្រ
ភាយមន្តអាគមខ្សឹប។ ឲ្យកើតបានជាអ្វី។ តាម
បំណង (ឥស្សីជប) ។

- **ជប់** ជា កិ. គឺជញ្ជក់, ស្រូប, បឺត (ម្ជុយជប់

បង្កើយកូន) ។

— ជាប់ ជានាម គឺកន្សែងដែលបិត ស្របយកទឹក (ជប់ក្តុំ) ។

៤- ពាក្យផ្ទួយ នឹង :

— សាមគ្គីរតន គឺ សាមគ្គីភាព

(សាមគ្គីភេទ្រៃថា ការបែកសាមគ្គី; អ្នកបំបែកសាមគ្គី ហៅសាមគ្គីភេទ្រកៈ; ឯសាមគ្គីប្ដី ភាព សាមគ្គីភាព គឺភាពនៃសាមគ្គី ភាពប្ដីសេចក្តីព្រមព្រៀង, ភាពស្រុះគ្នា) ។

— មហិច្ឆតា គឺ អប្បិច្ឆតា ឬ អប្បិច្ឆតាភាព

(មហិច្ឆតា ប្រែថា សេចក្តីលោភលន់; ឯ-អប្បិច្ឆតា ប្រែថា ភាពឬបែបបទនៃអ្នកដែលមានសេចក្តីប្រាថ្នាតិច ។ ឧទាហរណ៍ : ចិញ្ចឹមជីវិតដោយអប្បិច្ឆភាព) ។

- **អរិយធម៌ គឺ អនារ្យធម៌**

(អរិយធម៌ ឬ អារ្យធម៌ *គឺធម៌ដែលនាំឲ្យកើតសេចក្តី*
សុខចំរើន ។ ឯ អនារ្យធម៌ ឬ អនាយ៌ធម៌
គឺធម៌ដែលនាំមកនូវទុក្ខសោក សេចក្តីវិនាស)

- **ភូដិសព្វភាព គឺ ទាសភាព**

(ភូដិសព្វភាព *ប្រែថា ភាពជាអ្នកជា ។ ឯ*
ទាសភាព *ប្រែថា ភាពនៃមនុស្សដែលជាខ្ញុំ*
កំដរ ជាបាវព្រាវគេ ។ ចំពោះមនុស្ស
ខ្លះត្រូវសម្លាប់ ឬ ខ្លះត្រូវជា ប្រើនតែជាក់
ក្តីទាសភាព) ។

x

x x

ទី ១៧ - មនោសញ្ចេតនាចំពោះ «អតីតសម័យនៃមាតុភូមិ»

នៅក្នុងវៃ្រដែលដុះព័ទ្ធបុរាណប្រាសាទនានា មានរបស់

ពីរយ៉ាង ដែលនាំបង្កើតជួងចិត្តទេសចរឲ្យរីករាយស្រេច-

ដោចខ្លាចផ្សា ដោយសេចក្តីស្អាយអាល័យដល់គេរស្មាដៃនៃ

បុព្វបុរសខ្មែរ ។ វត្តនោះហាក់ដូចជាខ្សែព្រលឹងនិងសម្លេង

នៃប្រវត្តិមាតុភូមិយើង ។

. . វេលាដែលព្រះសុរិយា កំពុងដុតចំហុយអស់ទាំង

ធម្មជាតិ រៃកណ្តឹងយំទម្ងាក់សំឡេងពីចុងស្រោទ្បាប្តូរចុងឈើ

ទាល់ដែលលួតលាស់ខ្សែត្រដែតឮដំរេហាស ។ ស័ព្ទសូរ

តន្ត្រីចម្រែកនេះជ្រាបចូលសព្វសព៌ាង្គកាយ ហើយមកវ៉ំ

ក្រសោបបេះដូងនាំឲ្យអ្នកដំណើរទាំងពួងយន់ចិត្ត អាស្រូវដល់

ស្រែកំណើតដែលធ្លាប់ឃ្លាតកុក ។

នៅខេត្តនិងខេពិសាខ តាមផ្លូវពីក្រុងសៀមរាបទៅ

អង្គរ ផ្ទាំងដូលបន្លេញកំនរកើយពាងក្រអូបឈួយឈ្ងប់ ។

បើជួនជាមានវាយោបក់បន្តិច ។ ផង អ្នកដែលដើរយកអាកាស

ពេលល្ងាចតាមថ្ងៃនេះ នឹងមានចិត្តរសាប់រសាយអណ្តែត

អណ្តូង ប្រហែលជានឹងលាន់មាត់ថា ពោះជាស្ថានតុសិត

កំមិនសប្បាយជាជាងនេះទេមើលទៅ ។

តូចំនរំដួល! ខុសំឡឆៃ! កម្ចាំងអ្នកជួបជាពិព្វខុសថ
ដែលអាចបូលមកសំលាយសេចក្តីសោកសង្រ្តែង មួយពេល
ឃាន ។

នៅពេលរសៀល រាទេះសេះមួយបរបូលតាមក្រោងទ្វារ
មកកំពង់តំពែងនគរធំ ។ ត្រាចៀកប្រុងស្តាប់ ភ្នែកប្រុងមើល
នាងវិជាវីអង្វរអែបនឹងមាតា ដែលនិយាយចេកចាចនឹងនាង
គឺ

សុំចំត្រៀ គ្មានឈប់មាត់ឡើយ ។ នាងស្រីក្រមុំតែងតែកំចិត្ត
ថា: "ខ្ញុំពុកណាស ម្ល៉ះសមមានមនុស្សអ្នកអ្រ កុំកាម៉ាដេរ
ជាស់អានេកអន័ត្ស ,, ។

ម្តេចឡើយឥឡូវកំលេចាយជាត្រែអស់រលឹង មុខគួរឲ្យ
ស្រណោះពេក ។

ដាំស្រែពោធ

សំណួរ

១- ចូរពន្យល់ពាក្យ ខេសចរ, ប្រវត្តិមាតុភូមិ, សញ្ជ័ឆ្កាយ, ពិដោរ, ទំព្នុសថ, អនេក-អន័គ្ឃ ។

២- ក) ពាក្យ "ប្រព្រឹត្ត" សរសេរបានប៉ុន្មានបែប ? តើអ្វីខ្លះ ?

ខ) ពាក្យ "អច្ឆរិយ" សរសេរបានប៉ុន្មាន យ៉ាងដែរ ? តើអ្វីខ្លះ ?

៣- តារមនុស្សប្រភេទណាខ្លះ ត្រូវកនាមនិងករណា នាមប្រភេទគ្នាយ៉ាងណា ? ចូរកត់ចារណ៍ក្នុងអត្ថបទខាងលើមកបញ្ជាក់ឲ្យបានមួយៗ ។

៣- ចូរដ្ឋិសង្ខេបប្រយោគ "វេលាដែលព្រះសុរិយា កំពុងដុត . . . ឮដំរែហាស៍" ។

មធ្យមសិក្សាបឋម

លើកទី២ ថ្ងៃ ៤-៩-៦៦

កំណត់ចំណាំ

១. ពន្យល់ពាក្យ

- **ឧទ្ទេសចរ** ជនអ្នកធ្វើដំណើរលំហែកំសាន្ត ។ (កុំ
ច្រឡំនឹងទ្វេសបរិណាមគឺការធ្វើដំណើរកំសាន្ត
លំហែចិត្តនៃជនបរទេស ឬក៏ជាឈ្មោះក្រសួង
រដ្ឋមន្ត្រីកាន់កាប់ខាងវិស័យការនេះ គឺក្រសួង
ទេសចរណ៍) ។

- **ប្រទេត្តិមាតុភូមិ** ដំណើរវឿងរ៉ាវ ឬសាវតារនៃ
មាតុភូមិ គឺវឿងរ៉ាវនៃភូមិកំណើត ទឹកដីនៃ
ទឹកដីដែលយើងកើត ។

- **សព៌ាង្គកាយ** (អាចសរសេរ សពិង្គកាយ)
គ្រប់រូបពងកាយទាំងមូល ។

- **ពិរុជារ** ដែលមានភ្នំនក្រអូបល្អ ដែលក្រអូបសាយ
(ភ្នំនពិជោរ, ឆ្ងុំពិជោរ) ។

- ធិញ្ញជិសជ ជាំទំព្ញ ។
- អនេកអនន្ត ដែលប្រើនគាត់ថ្លៃពុំបាន ។

២- អក្ខរាវិរុទ្ធ

- ឧទសចរ (សរសេរ រ ចុង) ។
- រឹតត (សរសេរ រ ស្រៈ ឹ និង ត ពីរ) ។
- ជ្ឈរ (សរសេរគ្មាន រ ចុងទេ) ។
- អាឆរ័យ (សរសេរ ឆ្ងំ និង យ) ។
- ជម្ងាក់ (សរសេរតម្រូត ព្រោះមកពី ធ្លាក់) ។
- ជាល (សរសេរ ឡ និង ល) ។
- សកាំង្គកាយ (អាចសរសេរជា សរីរាង្គកាយ បាន) ។
- ទ្រ (សរសេរ ស្រៈ ុ) ។
- ចក្រត្រ (អានថា ចៃត្រ ។ សរសេរ ច និង ត្រ) ។
- ពិសាខ (សរសេរ ព - ស និង ខ) ។
- ភ្ញិន (សរសេរ ភ្ញ និង ជ) ។

- ពិរជ្ជារ (សរសេរ រ ពុង) ។

- ស្ដាន (អាចសរសេរ ហ៊ាន ដូចខ្មែរបាន) ។

- តុសិត (អានថា ដុះ - សិត ។ សរសេរ ត្ថ - សិត ។ សិន្ធ ត) ។

- ន៊ូរនរ (អ្នរ មាន រ ពុង) ។

- ក៊ុះករមីរជរជ្ជាសំ (ករ, មីរ, ជ្ជៃរ សរសេរ មាន រ ពុង) ។

- អរេឯករអង្គ្ស (អង្គ្ស សរសេរ ង ន ធ គ្ស) ។

៣- សទិសសព្ទ នៃពាក្យ .

១- ជ្ជារ :

- ជ្ជារ ជានាម គឺទីប្រជុំលក់ទិញរបស់ផ្សេងៗ (ផ្សារ ផ្សា) ។

- ជ្ជារ ជាកិ. ប្រ គុ. ប្រែថា ឈឺចាប់ ពេលកាល កាលធ្វើបាបដោយមុខសស្ត្រា, វប្ប, ជាប់, រលាត់, ប៉ះពាល់ត្រូវ ប្រទះឆ្លងជាតិជ្ជរប្រែហ៊ីរ

(ខ្វាចផ្សា) ។

- ជ្រួរ ជាអា.និ. ប្រែថា ព្រោះ, ហេតុនែ, ដោយ ហេតុ, តាមនែ(ផ្សាន់ធឹងបាន តែចង់នែធឹងបាន)។

ជ្រួរ ជាកិ. ប្រែថា ផ្សងតាមកម្ម, ផ្សងព្រេង, ច្រំច្រ, ច្រំអត់ (ផ្សាជាអ្នកកម្សត់) ។

- ជ្រួរាន ជាកិ. គឺភ្ជាប់ភ្ជិតដោយទឹកបន្សាវ(ផ្សារឆ្នាំង)។

ញ - ន :

- ញំ ជាកិ. គឺគ្រែសោបព័ន្ធដិតជុំវិញ, បង៉ព័ន្ធ, ម្លូវព័ន្ធ (រុំវែង, រុំរបួស) ។

- ន ជាកិ. ប្រែថា ទន្លូគ្រែបន្ធូនបង្ហប់កំស្បូលចំហាយ ផ្សែង។ ដែលសោរថ្នាំ ឲ្យក្តៅចេញរាញ៉ីសពី សពាង្គកាយ ដើម្បីឲ្យស្រាលខ្លួន, ឆ្លង (រំឲ្យជា ភេតឫសដូចវិល) ។

- ន ជាគុ. ឬ ទាម គឺដែលដុះក្រោយបន្ទាប់នែប

នៃបន្ទឹងគេ (ខ្នែងរម្ង គឺខ្នែងតូចដែលដុះក្រោយ ហើយអែបនៃបន្ទឹងខ្នែងធំ ។ ឬរម្ងគឺជាគោតជារដើមដែលដុះលេចក្រោយ ដូចជាស្មៅតផ្កាប់នឹងផ្កាធំ ហៅថា ក្បូនរម្ង ក៏បាន ។ ឈើគគីនេះមានដុះរម្ង ច្រើនណាស់) ។

ចំណារ .-

ពាក្យដែលមាន :

១- នាមពីរមុខ : រមណី, រមណីយ, រមណីយដ្ឋាន, រមណីយប្បទេស, រមណីយវ័ន, រមណីយាកម, រមណីយោទ្យាន, រមទម ឬ រម្យទម ។

២- នាម ពីរក្រោយ: អកិរម ឬ អកិរម្យ, មនោរម ឬ មនោរម្យ ។

៣- នុំ ពីមុខ: នុំកោះ (ដែលស្រមកប្រើនជាន់ ច្រើនស្រទាប់ ។ ក្អែលនុំកោះ, សូត្រដំពាក់នុំកោះ ដំពាក់ចំណុលគេនុំកោះ) ។

៤ - នំ ពីរមួខ រំកាប់, រំកាប់មាស, រំកាប់រំកោច, រំកិល, រំខាន, រំគងកែវស្នេហ៍, រំគាយ, រំគាល រំគេញ, រំឆកប្អូរមួក, រំឆាចប្អូរមួច, រំឆាប់ ប្អូរមួប់, រំឆាស់ប្អូរមួស់, រំឆឹកប្អូរមើ្ក, រំចាក, រំចឹដែ, រំចេក, រំជា, រំដឹក, រំជីរំជា, រំដួល, រំដើប, រំដេញ, រំដែ, រំដែក, រំដំរំដែង រំដាក, រំដួល, រំដេក, រំដេង, រំដេញ, រំដេញ មាស, រំដោះ, រំទំប្អូរមេទម, រំបល់, រំប៉ុក, រំពង, រំពត់, រំពា, រំពាត់, រំពាស់, រំពឹង, រំពើក, រំពើន, រំពេ, រំពេច, រំពេន, រំម៉ៃ, រំភាយ, រំភើក, រំភើប, រំភើយ, រំយាក, រំយឹក, រំយោល, រំលង, រំលត់, រំលប់, រំលស់, រំណា, រំលាក, រំលាង, រំលាយ, រំលិច, រំលឹង, រំលឹក, រំលុង, រំលុប, រំលុះ, រំលូត, រំលើក, រំលើង, រំលៀក, រំលៀង,

រំលេច, រំលេច, រំលែម, រំលេះប្តូរំលែះ, រំលែក,
រំលោក, រំលោធ, រំលោក, រំលំ, រំសាយ,
រំសុះ, រំសេវ, រំសោះ, រំហ, រំហ័ស,
រំហាច, រំហុក, រំហួត, រំហួត, រំហើយ,
រំហែ, រំហោក, រំអា, រំអិលប្តូរំផល, រំអុក
រំអួយ, រំអើក, រំអែធ, រំអែរំអួយ, រំឮក ។

៣- ចែត .-

- **ចែត** ជានាម គឺឈ្មោះភាំបិតផ្នែងំវែង ជង្វី (ភាំ-
បិតចែត) ។

- **ចេត្រ** ជានាម គឺឈ្មោះខែទី ៤ នៃចន្ទគតិ (ខែ
ចេត្រ) ។

៤- រាប .-

- **រាប** ជាគុ. គឺដែលមិនរដិបរដុប, ដែលឥតប៉ោង,
ឥតខ្ចុះស់ទាប (ដីរាប, ផ្លូវរាប, ឫកពារាប-
ទាប, សៀមរាប) ។

- វៀប ជាកិ. គឺធ្វើឲ្យមានរបៀប (រៀបផ្ទះ, រៀប-ស្រុក); តែង, ប្រដាំ (រៀបខ្លួន), ចាត់ការ ធ្វើអាពាហ៍ពិពាហ៍ឲ្យគាមរបៀប (រៀបកូនឲ្យមានផ្ទះសម្បែង) ។

- វៀបនឹង ឬ វៀប ជានិ. គឺរៀប, ហៀប, ជិតរកគល់ (រៀបស្លាប់, រៀបនឹងខ្យល់) ។

ចំណារ. -

ពាក្យមានន វៀប ម្យ៉ាង : រៀបចំ, រៀបរាប, រៀបរាប់ រៀបរយ, រៀបរៀង ។

x

x x

ទី១៨— រុក្ខទិវា

នៅឧកាសដែលសម្តេចទ្រង់បញ្ជាឲ្យព្រះរាជាកំចាលប្រារព្ធ រៀបចំពិធីរុក្ខទិវានេះទៀត មានប្រជាពលរដ្ឋខ្លះបេះតែនឹកឆ្លៀតក្នុងចិត្ត ហើយចង់ដឹងនូវប្រយោជន៍ ព្រោះអ្នកទាំងនោះមិន

ដែលប្រទេះព្រឹត្តិការណ៍នេះសោះ ។

តែប្រសិនបើយើងរំគិតមើលវា យើងនឹងអស់សង្ស័យ
មិនមាន ដ្បិតពីរបៀបនេះជាទំនៀមទម្លាប់ខ្មែរតាំងពីបុពណ
កាលរៀងដកបមក ដូចជាបុណ្យដាំដើមពោធព្រឹក្សដែលមាន
គោលបំណងផ្សាយដំនឿខាងព្រះពុទ្ធសាសនា ហើយនិងផ្តល់
ផ្លមនុញ្ញផលដល់ពុទ្ធសាសនិកជនដែលមានបសាទសទ្ធាជ្រះ
ថ្លា ចូលរួមកងបពាកម្មនេះ ។

រីឯរុក្ខទិវាវិញ ចង់ញុំាងពលរដ្ឋឲ្យស្គាល់យ៉ាងប្រត្យក្ស
នូវអត្ថប្រយោជន៍នៃឈើក្នុងបច្ចុប្បន្នជាតិ ។ ឈើបំរើមនុស្ស
សិន្ទស្មាលណាស់ តាំងពីយើងចាកឧទរបស់មាតារហូតដល់
រំលាយខន្ធទៅវិញ ។ យើងតែងយកឈើមកធ្វើជាឧស លំនៅ
ហានិងឧបករណ៍ផ្សេងៗ ។ ម្យ៉ាងទៀត ព្រៃឈើមានមុខ
ងារជាអាថ៌កំបាំងខាងធ្វើឲ្យក្រៀងជ្រាក់ និងទប់គង្គាកុំឲ្យជោរដែន
លិចភូមិហាន ដែលសាមញ្ញជនមិនងាយយល់ឡើយ ។ ម្យ៉ាះ
ហើយអ្នកបច្ចេកទេសតែងចំរៀតយកថ្ងៃដាំកូនឈើម្តងៗដើម្បី

ធ្វើជាវាគ្មិន ពន្យល់អ្នកផ្ទះឲ្យស្គាល់ក្នុងវិស្សាស្ត្របស់ខ្លួន ។
ក្រៅអំពីនេះ ព្រៃឈើជារមណីយដ្ឋានអាចទាក់ចិត្តនិងបំពេញ
អារម្មណ៍ទេសចរទាំងឯកាយ ឲ្យរស្ប៉ីយរហ័យក្នុង ហើយ
ក្សេមក្សាន្ត ។

ទោះបីមានគោលដៅថ្មីក្តី ការងារប្រកបតាមប្រពៃ
ណី ឬតាមសម័យនិយមស្មុគស្មាញមានសារៈសំខាន់ដូចគ្នា សម
ន័ឍសុភាសិតឥណ្ឌាមួយថា "អ្នកណាបានដាំឈើមួយដើម
មុននឹងស្លាប់ទៅ មិនមែនបានរស់នៅឥតប្រយោជន៍ឡើយ" ។

សំណួរ

១- ឆ្លើយនៃពាក្យ រក្ខទឹក, ស្រោរព្ធ, ឥដ្ឋមន្ទាឥល, ឋាពកម្ម, វាគ្មិន, វនវប្បកម្ម ។

២- ចូររកសព្ទញ្ជាតិ នឹងពាក្យ "ប្រជា" ដោយ
ឲ្យន័យនៃពាក្យនីមួយៗផង ។

៣- សមាសនាម និង សម្ភូមានាម មានការ
ប្លែកគ្នាយ៉ាងណា ? ចូរស្រង់ឧទាហរណ៍

ដែលមាននៅកន្លែងហ្នឹង ''ទៅទុកាសដែលសម្លេច .... ព្រឹត្តការណ៍នេះសោះ'' ដោយបញ្ចាក់ពាក្យនីមួយ ។ ទៅតាមប្រភេទនៃនាមទាំងពីរយ៉ាងនេះ ។

៤- ឈើមានឆ្យូរយោជន៍ អ្វីខ្លះបំពោះមនុស្ស ?

(៤)

អធ្យមសិក្សាបឋម

លើកទី ១ ថ្ងៃ ១៨-៦- ៧

កំណត់ចំណាំ

១- ពន្យល់ពាក្យ -

- **រុក្ខជាតិ** ថ្លែបុណ្យក្រាវឆ្នូតពីធដាំដើមឈើជា
ទំម្លាប់នៃការរក្សាគ្រួង បង្កើនព្រៃឈើ ។
- **ប្រោះព្រួ** តាំងផ្តើម, ផ្តួចផ្តើម, ប្រុងប្រៀប, រៀប
រប. ទឹកដើម, គំនូសល់, ភ្លក់ទឹកដល់ ។
- **ផ្តួមន្ទុញដល** ផលជាទីពេញចិត្តដែលបាន

សម្រួចដូចបំណង ។

- ទាក្ខិណ អ្នកឈ្លាសសំដី, អ្នកមានសំដីថ្លៃមាត់ (l'orateur) ។

- ទឆទប្បកម្ម ការបណ្តុះបណ្តាល បង្កើតបង្កើន អាជីវកម្រៃ ។

២- សព្ទញ្ជោតិ នៃពាក្យ ប្រជា :

- ប្រជា គឺពួកសត្វ, ពួកជន (ប្រជាករ) ។

- ប្រជាករ ឬ ប្រជាជន គឺពួកជនចំណុះប្រទេស (le peuple) ។

- ប្រជាជាតិ គឺជាតិនៃមនុស្សដែលមានវប្បធម៌ទូលំទូលាយជាមួយគ្នា (la nation) ។

- ប្រជាធិបតី គឺអធិបតីរបស់ប្រជា (ព្រះរាជា) ។

- ប្រជាធិបតេយ្យ គឺការពារនៃប្រទេសដែលមានប្រជាភិបាលអធិបតី គឺប្រទេសប្តូរដូចគ្នាដែលមានប្រជាជនជាធំ ក្នុងការរើសតំណាង

របស់ខ្លួន ឲ្យជាអ្នកសម្រេចកិច្ចការក្នុងប្រទេស

(la démocratie) ។

- ប្រជាធិកៈ គឺពួកប្រជារាស្ត្រ, ពួកមនុស្ស

(la population) ។

- ប្រជាពលរដ្ឋ គឺពលរដ្ឋប្រជាជន (le peuple)។

- ប្រជាតិចុតិ គឺការបញ្ជោរឬការបញ្ឆោចលើការដឹង

ប្រជារាស្ត្រ (la démagogie) ។

- ប្រជាតិបាល គឺអ្នកគ្រប់គ្រងប្រជាជន (ព្រះ

រាជា) le gouvernant, le gouvernement

- ប្រជាតិទណ្ឌ គឺការលូតលាស់ដុះដាលរបស់ប្រជា

រាស្ត្រ, ការបណ្តុះបណ្តាលមនុស្ស សត្វ ត្រង់

តំបន់ដែលមិនធ្លាប់មានក្នុងការសម្រុន ឲ្យកើត

មានឡើង ឲ្យបានកែបម្រែនឡើងជាលំដាប់ៗ

- ប្រជាមតិ គឺមតិ ឬយោបល់ប្រជារាស្ត្រ (le

référendum) ។

- ប្រជារម្យាដិត ដែលប្រជាជនចូលចិត្តស្រឡាញ់ ពាក់អាន, ដែលគាក់ទងដល់ប្រជាពស្ត្រ, ដែលមានផលប្រយោជន៍ដល់បណ្តាជនទូទៅ (populaire) ។

- ប្រជារស្ត្រ ឬ រាស្ត្រប្រជារ គឺពួកជនចំណុះដែន (le peuple, la population) ។

- ប្រជារប្រិយ គឺដែលប្រជាពស្ត្រនិយម ស្គាល់ចូលចិត្ត (populaire) ។

- ប្រជារប្រិយតារ គឺការៈដែលប្រជាពស្ត្រពេញចិត្ត ទទួលស្គាល់ ស្រឡាញ់ ទំនុកទុកចិត្ត (la popularité) ។ ល ។

៣. អក្ខរាទិវុទ្ធ.-

- ប្រោវុទ្ធ (សាសេរ ប្រ-វ ធ ព្ធ) ។

- ជរាប (ជ គ្មានអស្ពាទ) ។

- ពុទ្ធសាសនិក (ពិក សាសេរ ពុ ធ ក) ។

- ស្ថិដ្ឋស្ថារស (ស្ថិ+ដ្ឋ សារសារ ស្ថិ+ដ្ឋ) ។
- ឱជារ (ជ្រៀមនរំចុង) ។
- ឱស (ភាពសារសារ អ្នស៊ ដូរប្តូរបាន) ។
- ឋាន (ភាពសារសារ ស្ថាធ បាន) ។
- ឧបករណ៍ (ការណ៍ សារសារ ក-រំនង ណ៍) ។
- គន្ថារ (គ្មានរំចុងទេ) ។
- ជោរ (មានរំចុង) ។
- តណ្ហារ (សារសារនឹងស្រៈ -1) ។

๔- សន្ធិសសព្ទ នៃពាក្យ :

๑- កាល :

- កាស ជានាម ប្រែថា គ្រា, ពេល, សម័យ, (កាលនោះ, កាលបរិច្ឆេទ) ។
- កាល ជានាម ប្រែថា មច្ចុរាជ, សេចក្តីស្លាប់ (ព្រះកាលតែងផ្តាច់ផ្តិលនូវអាយុសង្ខារនៃសត្វលោក) ។

- **កាឡ** (កាឡកណ្ណី) ជានាម គឺមនុស្សឥតបុណ្យ, មនុស្សចង្រៃ (ដូចគ្នានឹងពាក្យ កាឡកំណី វិញដែរ ថា មនុស្សធ្វើនូវនិស្ស័យនៃខ្លួនឲ្យប្រាកដ ស្មើដោយវត្តមានពណ៌ខ្មៅ (មនុស្សកាឡកំ-ណី, ស្រីកាឡកំណី) ។

- **កល្ប** ជានាម ប្រែថា កាលដែលតាំងនៅយូរអង្វែង (មួយកប្បមួយកល្ប, ក្លឹងឆេះកល្ប ប្តូរក្លឹងប្រល័យកប្ប) ។

២- ព្រឹក្ស :

- **ព្រឹក្ស** ជានាម ប្រែថា ឈើ (ខ្មែរប្រើនប្រើពាក្យនេះផ្សំជាបទសមាស រឿងខាងចុងនៃនាមស័ព្ទដែលជាឈ្មោះឈើផ្សេងៗ (ដូចជា : កល្ប-ព្រឹក្ស, ជម្ពុព្រឹក្ស, និគ្រោធព្រឹក្ស, ពោធិព្រឹក្ស) ។

- **ព្រឹក** ជានាម គឺវេលាចាប់តាំងពីព្រះអាទិត្យបំព្រាងដល់ថ្ងៃពេញពន្លឺធំ (ព្រឹកល្ងាច, ព្រឹកព្រាង) ។

៣- ឩស :

- **ឩស** ឬ **អ្ងុស** ជានាម គឺឈើសម្រាប់ដុត (រក ឩស, ជាចអ្ងុស, គនរអ្ងុស) ។

- **អ្ងុស** ជាកិ. ប្រែថា ពាញរំកិលដិតជាប់លើដី ឬ លើផ្ទៃទឹក (អ្ងុសខ្លួកចុះទឹក, អ្ងុសសម្រាស់) ។

៤- សា :

- **សា** ជាកិ. ប្រែថា ម្ហូរទៀងវិញ (សាកនេ្ងល); តេីបទៀងវិញ (សាស្រួវ); -ត្រឡប់វិញ (សាមកវិញ, ដេីរសាចុះ សាទៀង); - រេីឈើទៀងវិញ (សាឈើទៀងវិញ); - និយាយថ្លែងពីខ្លួក (និយាយសាខ្លួក); - និយាយជាថ្មីទៀត (សានិយាយម្ដងទៀត) ។

- **សា** ជានាម គឺដំណេីរត្រឡប់ទៅមក ឬចុះទៀង, ដង, គ្រា, ត្រឡប់, ជក (ដេីរមួយសាពីរសា)។

ជាប្តីប្រពន្ធ (ការភូន, ការចៅ) ។

– **ការណ៏** ជានាមប្រែថា ហេតុ, ដំណើរ (សេចក្តីពយការណ៍) ។

– **ការ** ជានាមប្រែថា បំពង់សម្រាប់ជាក់ទឹក (កាទឹក) ។

– **ការ** ជាកិ. គឺសរសៃអស់យដ្ឋាន ឈ្មោះអ្នកដែលនឹងទ្រួលសំបុត្រនៅលើស្រោមសំបុត្រ (កាខ្ទង់សំបុត្រ) ។

๓– ភព :

– **តព** ជានាម. ប្រែថា សេចក្តីចំរើន, ដំណើរ, កើត (នៅក្នុងកពរនេះ) ។

– **តប់** ជាកិ. ប្រែថា ដួប, ប្រទះ, ប្រសព្វ (តប់-ប្រសព្វ) ។

x

x x

ទី៨.- សិលាប្រាសាទ និង ខ្មែរបុរាណ

ប្រទេសកម្ពុជា ជាប្រទេសក្នុងតំបន់ដែលសម្បូរដោយសិលាប្រាសាទ ដែលជាគំរូដ៏ពិសេសនៃស្នាដៃបុរាណរបស់ខ្មែរជន ពីក្នុងបុរាណសម័យ ។ ប្រាសាទទាំង ដែលមានលម្អដ៏បវរ ស័ក្តិសមឥតមានពីរនោះ គឺប្រាសាទនគរវត្តដែលសព្វថ្ងៃហៅ ក្បាយជាអង្គរវត្ត ។ សិលាប្រាសាទនេះមានក្បួរក្បាច់រចនា ដ៏បណ្ដាច់អស្ចារ្យ ក្នុងថាតែមនុស្ស ពោះទាំងទេពតា ក៏គង់ និយមការសរសើរពុំខាន ។

តាមពាក្យបរម្បរថា ព្រះពិស្ណុការមកជួយសាង តែបើ តាមសិលាចារឹកជាភ័ស្តុតាងថា ជាការស្នាដៃនៃពួកពាជវង្សក្តី ជាមនុស្សជាតិខ្មែរសុទ្ធ ជាពួកកុលបុត្រ តក្កវិទ បេះពិនិត្យកិច្ច ការ ជាអ្នកបរិបូណ៌ដោយសិល្បវិទ្យាសាស្ត្រ សាងកិច្ចការ ព្រះកេតុមាលាក្បត្រាធិការជខេមរជាតិ ។

ខេមរជនសម័យបុរាណ ជាអ្នកមានអធ្យាស្រ័យគម្ភីរភាព

ពេញចិត្តនឹងការសិក្សាបំណែនវិជ្ជា ទាំងផ្លូវលោក ទាំងផ្លូវធម៌
ហើយឧស្សាហ៍ស្រែកស្រែទេញ រៀនទន្ទេញដោយការម៉ឺងម៉ាត់
ប្រយ័ត្នក្រែងសាបសូន្យការចេះដឹង ព្រោះហេតុហ្នឹងហើយបាន
ជាខេមរជនបុព្វបុរសរបស់យើងធ្វើសិស្សាច្រើនសែនប្លែកៗអនេក
អនន្តអស្ចារ្យ ស្ទើរតែនឹងគណនាត្រាប់ឲ្យសព្វគ្រប់ពុំបាន ។
ជាតំខែរកូនដំនាន់បុរាណ មិនមែនចេះត្រឹមតែការហត្ថ-
កម្មប៉ុណ្ណោះទេ សូម្បីតែកវីជ្ជា និងវិទ្យាអក្សរសាស្ត្រ ព្រមទាំង
សល្យសែរ ក្បួនច្បាប់ ក្រឹត្យក្រម តុរង្គតន្ត្រី កមានល្បីថាចេះ
គ្រប់មុខ ទុកបែបបទជាគ័ស្តុតាងឲ្យយើងឃើញច្បាស់ជាមួរ
សិលាចារឹកដ៏វិចិត្រ មានតែងគាថាជាពាក្យកាព្យឆន្ទសំស្ទើត
ដោយពិនិត្យពិច័យ ជាសម្ងាដៃនៃបណ្ឌិតកវីអ្នកប្រពន្ធ មាន
លក្ខណៈត្រឹមត្រូវគ្រប់គ្រាន់ ឥតមានវិបត្តិល្អៀងឃ្លៀងឃ្លាត
ខាតខុសឡើយ ។

សំណួរ

១— ចូរពន្យល់ពាក្យ ទាំងឡាយនេះ : តក្កវិទ,

គម្ពីរភាព, ស្រាស្រេចេញ, ក្រិត្យក្រម, តុប្ប
តន្ត្រី, សំស្ក្រឹត ។

២- ចូរអ្នកសង្កេតប្រយោគ : "ខេមរជនសម័យ
បុពណ ។ល។ គណនាត្រាច់ច្បាស់ពុត្រប់
ពុំបាន" ។

៣- មានអ្នកខ្លះពោលថា ខ្មែរមិនអាចកសាង
ប្រាសាទបែបឲ្យមានលម្អយ៉ាងនេះទេ គប្បាស
ជាព្រះពិស្ណុការមកជួយសាង, ខ្លះទៀតឆ្លើយ
ថា : គ្មានព្រះទេពតាណាជួយសាងទេ គឺ
ប្រាកដជាស្នាដៃ នៃពួកបុព្វបុរសខេមរជាតិ
យើង ។ តើអ្នកយល់ដូចម្តេចចំពោះមតិ
ទាំងពីរខាងលើនេះ ? ។

មធ្យមសិក្សាប័ត្រ

(លើកទី ២ ថ្ងៃ ២៦-៦-៦១)

កំណត់ចំណាំ

๑. អក្ខរាតិរុទ្ធ.-

- **សិលោ** (ន) ឬ (កុំច្រឡំនឹងពាក្យ សីលៈ ឬ សីលោ ចារ, សីលោ ឧស្សត្ត) ។

- **លម្ភ** (សរសេរតម្រង់ ពីព្រោះមកពីពាក្យ ឡភ ឬ ឡព្ភ ពីមុនសរសេរ លំអ ដូច្នេះ) ។

- **ឧពតា** (អាចសរសេរ ទ្វេព្យញ្ជនៈបាន) ។

- **ភ័ស្តុតាង** (អានថា ភ័ស្តុ - តាង; - សរសេរ ភ័ស្តុ - តាង) ។

- **ប្រយ័ត្ន** (យ័ត្ន សរសេរ យ៌ និង ត្ន) ។

- **សម្ភារៈ** (សរសេរតម្រង់ ពីព្រោះមកពីពាក្យ សម្ភ ។ ពីមុនសរសេរ សំណង រៈ) ។

- **អនគ្ឃ** (អាចសរសេរ អ៌ឃ បាន) ។

๒. ន័យរបស់ពាក្យ.-

- **បទរាសក្តិ** (ស.ន.) រុំរឿង ប្រៃសើរសក្តិសម ។

– **ពាក្យបរម្បរា** (ស.ន.) ពាក្យមិនពិត, ពាក្យនិ-
យាយតៗគ្នាពីមាត់មួយទៅមាត់មួយទៀត ។

– **ព្រះពិស្ណុការ** (ន) មកពីពាក្យ វិស្សកម្ម ដែល
ជានាមនៃទេវតា អ្នកមានបំណែះខាងការជាង
ជាអ្នកសម្រេចកិច្ចការថ្វាយព្រះឥន្ទ្រ ។

– **វឌ្ឍកី** (ន) ជាងឈើ (វឌ្ឍកីកម្ម = ការជាងឈើ)។

– **តក្កវិជ** (ន) អ្នកបែនតក្កវិជ្ជា គឺបែនវិជ្ជាត្រិះរិះរក
ហេតុផលដែលបែកឲ្យឃើញច្បាកដ ដោយ
គំនិតខ្លួនឯង (ដូចគ្នានឹងពាក្យតក្កវិញ្ញូ) ។

– **សិល្បីសារ្វស្ត** (ឬសិល្បសាស្ត្រ) (ន) ក្បួន
រៀនសិល្បៈ, បំណែះជាង ។

– **គម្ភីរតារ** (ស.ន.) ភាពជ្រៅ, ជម្រៅ ។

– **ស្រេងារស្រេងេញ្ជ** (ក.) ខិតខំ សង្វាតពេញ
កម្លាំង, ខ្វីឃ្មាត ។

– **ក្រិត្យក្រម** (ស.ន.) (ក្រិត្យ = ច្បាប់ដែល

តែងតាំងឲ្យអនុវត្ត = le kret, le décret ;

ក្រម = បញ្ជាប់ដែលរដ្ឋសភាអនុម័ត ហើយ

ប៉ុន្តែព្រះហស្តលេខានៃព្រះប្រមុខរដ្ឋសំរាប់អនុវត្ត

ជាច្បាប់ = la loi) - ក្រិត្យក្រម = លំដាប់

នៃកិច្ច ។

- **គូរឫគន្លឺ** (ន.) គ្រឿងក្វេងដេញដំផ្ទុំកូត ។

- **គាថា** (ន.) កម្រងវាចាដែលមានវរៈបៀបកំណត់

ដោយខ្សែអក្សរមាន ៤ នឹ្ម គណៈ ឃ្លា ល្បះ ។

- **សំន្តឹត** (ន.) ឈ្មោះភាសាដើមដំបូងបំផុតរបស់

ពួកហិណ្ឌូ ។

៣- សទិសសព្ទ នៃពាក្យ :

១- ស៊ីលៈ-

- **សីល** (ន) ការកាន់ប្តូរប្រព្រឹត្តល្អដោយគោយវាចា

(សីលកថា, សីលគុណ) ។

- **សិល្ប** (ន.) សរសេរបានជា សិល្បៈ ឬ សិល្ប៍

(រៀនសិល្ប៍, សិល្ប៍វិជ្ជា) ។

២- បិដ្ឋ.-

- **ចិត្ត** (ន) (ចិត្តត្រង់, ចិត្តល្អ) ។

- **ចិត្ត** ឬ ចិត្រ (គ. ឬ ន.) ដែលគេចិត្តហើយ, ដែលគេធ្វើដោយផ្ងួតផ្ងង់ (រូបចិត្រ, ចិត្រករ, ចិត្តវិជ្ជា ឬចិត្រវិទ្យា) ។

- **ចិត** (ក.) កាត់ជាចំណិត (ចិតបន្លែ) ។

- **ចិតសិប** (ប. សំ) ចំនួនដប់ ៧ ដង ។

x

x x

ទី៩.- ការហត្ថកម្មនៅវាលសោះខ្សល់

ដើម្បីឲ្យប្រជាពលរដ្ឋប្រកបដោយសុខុមាភាព ឧត្តង ឧត្តម
ពុទ្ធ
សមតាមសម័យបច្ចុប្បន្ន ព្រះបិតាឯកភព្វជាតិ ជាព្រះ
អគ្គមគ្គុទ្ទេសក៍នៃយើង ព្រមទាំងភជរដ្ឋាភិបាល បានពិនិត្យ
ពិច័យរៀបចំឲ្យអនុវត្តន៍នូវផែនការប្រាំឆ្នាំដោយមធ្យត ។

មិនមែនគ្រាន់តែព្រះអង្គទ្រង់ចំណាយកាយពលផ្ទាល់ព្រះអង្គដើម្បីទ្រង់បំពេញការហត្ថកម្មប៉ុណ្ណោះទេ ព្រះបិតានៃយើងទ្រង់ត្រាស់បង្គាប់ឲ្យមន្ត្រីគ្រប់ជាន់ថ្នាក់ អ្នកស្រុក កងរាជពលខេមរភូមិន្ទ យុវជន យុវតី ឲ្យចូលរួមធ្វើការជួនបណ្តាពស្ត្រគ្រប់ទុគ៌ម ជនបទ គ្រប់ភូមិ ស្រុក និងខេត្តនៃព្រះរាជអាណាចក្រ ។

នៅការជ្ឋានៃរាល់សោះខ្សល់ ជារឿងរាល់ថ្ងៃ វេលាព្រឹកព្រាងស្វាងអរុណាទ័យ សូរសំពួរត្រែបានបន្លឺឡើងខ្ទរខ្ទារ ទាំងវៃព្រឹក្សា កម្មការថ្នាប្រញាប់ប្រញាល់គាន់ចបបង្គីគ្រប់ ។ ដៃ ហើយចរចេញទៅបន្តកិច្ចការរបស់ខ្លួន ។ គេកាប់គាស់ដី ក្រោមស្បែរសែង ក្រោមក្បឿង ផ្លែ ឬក្រោមផ្កបន្លែព្រះព្រៃមាក៏ពិតមែន ប៉ុន្តែគេសោមនស្ស សប្បាយរីករាយ ។

ពុះពារការងារឧបសគ្គនានា យកជ័យជំនះលើធម្មជាតិសម្រាប់ជាប្រយោជន៍ជួនប្រទេសជាតិ ។

ព្រោះហេតុហ្នឹងហើយ បានជានៅពេលធ្វើការ គេឮ

សូរសព្ទសំណើចអឺងអាប់ផុសចេញពីការសន្ទនាគ្នា ជាការកំ
ដរនិងលំហែបរិយាកាសជានិន្ន័ ។ ប៉ុន្តែមិនយូរប៉ុន្មាននេះឡើយ
លទ្ធផល គឺផ្នែកនៃការប្រឹងប្រែងនៃកម្មវិធីប្តីគ្រប់មជ្ឈដ្ឋានក៏
បានលេចជារូបរាងឡើង ។

ខ្ញុំបន្តឹកនៅវាលសោះខ្សាច់មានសណ្ឋានធំ បានលាត
លូនសន្ធឹងរូបស្តុកស្តឹងយ៉ាងប្រកបត្បំពោះមុខយើងពាល់គ្នា ។
ពេលនោះសម្តេចត្រង់យាងទៅធ្វើបុណ្យសម្ពោធយ៉ាងអធិកអ-
ធម មានប្រជារាស្ត្រកុះករឈូនរ ចូលមកអបអរសាទរក្រាប
ប្រណិបត្តន៍សំដែងស្វាមីភក្តិបំពោះព្រះអង្គ ។

ក្នុងស្មូនរកថាមួយយ៉ាងវែង ព្រះអង្គបានបញ្ជាក់ប្រាប់ក្មួន
ៗថា “ការសាមគ្គីគាជាធ្នឹមួយ អាចផ្តល់នូវអត្ថប្រយោជន៍
នូវឱ្យនភាពនិងជោគជ័យជូនជាតិ ដូចមានខំនបន្តឹកនេះជា
កស្តុតាងស្រាប់” ។

សំឆ្លូរ

១– ចូរពន្យល់ពាក្យ សុខុមាលភាព, អរុណោ-

ទំយ, អធិកអធម, វិវឌ្ឍនភាព ។

២- ចូរបង្ហាញន័យ នៃពាក្យ "មហា" និង ពាក្យ "ឧត្តម" តើខុសគ្នាយ៉ាងណា ? ឧទាហរណ៍ ។

៣- គាមគំនិត នៃការសរសេរតាមសូត្រនេះ តើ ការហត្ថកម្មមានតម្លៃយ៉ាងណាខ្លះ ?

កំណត់ចំណាំ

១- អក្ខរាតិរុទ្ធ .-

- ហត្ថកម្ម (ហត្ថ សរសេរ ត្រង់ដើម ១ ។ កុំ ច្រឡំ ហត្ថ ន១ ហស្ត ។ ចុះហត្ថលេខា, ត្រង់ឡាយព្រះហស្តលេខា) ។

- ព្រះបិតាឯកឝ្យរាជ្យ ឯកវាជ្យ ជានាម ។ ច្រ ទេសឯក រាជ = រាជ ជាគុណនាម) ។

- មគ្គុទ្ទេសក៏ (អាចសរសេរជា មគ្គុទ្ទេសក៍ ដូចប្លែកបាន) ។

- ពិចិយ (សរសេរ ប័ ន ធ យ ។ គ្មានដើម (ូ)ទេ) ។
- មច្ឆរ្យ (សរសេរ ម-ច្ឆ៍ ន ធ ព) ។
- ទុគ្គិម (អាចសរសេរ ទុរ្គម ដូចគ្នាបាន) ។
- ខែត្រ (អាចសរសេរ ក្សេត្រ ដូចគ្នាបាន) ។
- ក្រីកក្រោច (ក្រោង ខុសពីក្រៀងលាន) ។
- សូរសព្ទ (ស័ព្ទ អាចសរសេរ សព្ទ ដូចគ្នាបាន)។
- ខ្លួនខ្លាង (សរសេរ ន ខាងចុងដូចគ្នាទាំងពីរពាក្យ) ។
- សោមនស្ស (សរសេរ ស៊ ដើម -ស្យ) ។
- ឆ្ងារ (មាន ន ខាងចុង) ។
- ធម្មជាតិ (សរសេរ ធម្មជាត ដូចគ្នាបាន) ។
- សង្រ្គាម (សរសេរតម្រូត ពីព្រោះមកពី ស្រាប់ ពីមុនសរសេរ សំរាប់) ។
- កំណរ (សរសេរ ន ចុង ។ ពីមុនសរសេរ កម្ម ដូចគ្នាបាន តែឥឡូវឈប់សរសេរយ៉ាងនេះ ហើយ) ។

- **ឈំរំហា** (អាចសរសេរ រំហែ ដូចខ្លះបាន ។ គ្មាន រ ចុងទេ) ។
- **ឯិរន្តរ៍** (សរសេរ ឯិរឯិរ ដូចខ្លះបាន) ។
- **ឈន្ធឈស** (ឈ ទ្វេ សរសេរគ្មាន (់) ទេ) ។
- **សម្ភោធ** ជា កិ. (ប្រើជានាម សរសេរ សម្ភោធ ឬ សម្ភោធ៌ ។ ដូនតាលេខសរសេរ សម្ភោជ ឬ សម្ភោទ្យ ដូចខ្លះក៏មាន) ។
- **អធិកអធម** (អានថា អ:ធិក-អ:ធំ) ។
- **កុះករ, ឈូឆរ, អបរអរ, សាធរ** (ករ, ឆរ, អរ, ទរ សរសេរ រ ចុង) ។
- **ប្រណិបត័តន៍** (សរសេរ ប័-ព័ ន៍ ឯ ន៍) ។
- **ស្វាមីភ័ក្តិ** (អាចសរសេរ ភក្តិ ដូចខ្លះបាន) ។

២- ពន្យល់ពាក្យ :

- **សុខុមាលភាព** ភាពនៃបុគ្គលអ្នកមានសេចក្តី

សុខ, ការដែលធ្លាប់តែស្រណុក ។

- អនុវត្តន៍យ (មកពី សំ. ក. អនុ+ឧទ្ធយ ប្រែថា "ការរះឡើង" ការរះឡើងនៃអរុណ, គឺពេលអរុណរះ, វេលាថ្ងៃរះ ។

- អធិកអធម (មកពីសំ. ក. អធិក = ក្រៃលែង, លើសលែង, លើសលន់, រុងរឿង, ហ៊ឺកហ៊ាត់ +អធម=ថយចាក, ចាកឋាន, មិនរុងរឿង, "រេម៉ះរេម៉ាះ, ភយវង, បន្ទាប់បន្សំ = ខ្មែរប្រើពាក្យនេះចំពោះតែពីធីបុណ្យ ដែលរុងរឿងផង "រេម៉ះរេម៉ាះ របូចរប៉ូកយវង្សខ្លះផង ។

- វិវឌ្ឍនភាព (ក. វិឌ្ឍន: = សេចក្តីចំរើន + ភាវ: = ភាព) ភាពចំរើន លូតលាស់ ។

៣- សន្ធិសម្ព័ន្ធ នៃពាក្យ .

១- អប :

- អប ជា ន. ជាបុព្វបទសម្រាប់រឿងភ្ជាប់ពី

ខាងដើមសព្ទដទៃ មានសេចក្តីថា "ប្រាស
ចាក, ឃ្លាតចាក, ឃ្លាងចាក, ឆ្ងាយ, ទៅឆ្ងាយ,
ត្រឡប់, ត្រឡប់ជា, បែរជា, ផុត, រួចផុត, មិន,
ឥត (អបគតណ៌, អបច័យ, អបទេស, អប
ទ្រព្យ, អបធន, អបមង្គល ឬ អពមង្គល, អប-
លក្ខណ៌) ។

- **អប្បរ** ជា គុ. ប្រែថា តិច, តួប, ស្តួចស្តើង
(អប្បទ្រព្យ, អប្បធន, អប្បបញ្ញា ឬ អប្បប្រាជ្ញ)

- **អរាម** ជា គិ. ប្រែថា ជាត់ប្រាត់កាត់ ឬលុយ
ឲ្យទៅអ្នកទំញ (គេអាប់លុយឲ្យខ្ញុំលើស) ។

- **អរាម** ជា គុ. ប្រែថា ដែលអន់ ឬតិចពន្លឺ, ថយ
លំអ, ទៅក, ទន់ខាប, ខ្សោយ, តិច (អាប់
គំនិត, អាប់ជាតិ, អាប់ម្ខុ, អាប់អ្ម, អាប់អូន
ឬអាប់ខុន) ។

- **អរញ្ញ** ឬ **អរ័ញ្ញ** ជានាម គឺពពកខាប់ ឬ ពពក

ក្រាស់ (មេឃប៉ុះអ័ព្ទ) ។

២- កាំ :

- **កាំ** ជានាម ប្រែថា ថ្នាក់, ជាន់ (កាំផះណ្តើរ, កាំ. វេះ)

- **កាម្ម** ជានាម ប្រែថា អំពើ (វេរកម្ម, កម្មករ) ។

x

x x

ទី១០- . . . . . (១)

នៅពេជជានីក្នុងពេញ្ញ មហាជនប្រុសស្រី ក្មេងចាស់និង ពួកអ្នកទេសចរបរទេស បាននាំគ្នាទៅមើលព្រះរាជពិធីអុំទូក លយប្រទីបផ្សាលា និងសំពះព្រះខែ ដែលបានរៀបចំធ្វើឡើង យ៉ាងអឹកធឹកជាងពីឆ្នាំមុន ។ ។ ក៏ឮប្រណាំងទូកនេះ ជា កម្មាមួយជធអស្ចារ្យនៅប្រទេសកម្ពុជា មិនឲ្យបាត់បង់ទៅណា

(១) អត្ថដើមគ្មានឈ្មោះទេ ។ សៀវភៅសហជីវិន ជឹម - ទ្រ៧ ឈ្មោះ សរសេរតាមសូត្រឌីប្លូម បេញ្ញាំ ១៩៦៣ បានពិគ្រោះនិងខ្ញុំដាក់បំណងដើងថា "ព្រះរាជពិធីអុំទូកលយប្រទីប" ។

សាធារណៈរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
លេខចុះ: ...
លេខបញ្ជី: ...

បានរក្សាទុកបំនួនប្រទេសតរួមកាហើយ ។

នៅកងសួនបារជិរបត្រដោយទឹងយ៉ាងល្អស្អាត ទឹង
ដោយរុក្ខជាតិពណ៌ផ្សេង ។ នៅលើផ្ទៃនៃស្មៅយ៉ាងខៀវខ្ចី
បញ្ចាំងដោយពន្លឺអគ្គិសនីដ៏ភ្លឺថ្លា មហាជនប្រុសស្រីតុបតែង
ខ្លួនយ៉ាងល្អគ្រប់ ៗ គ្នា ឈរនិងដើរវេកមៀងមើលប្រទិបនិង
កាជ្រួចដែលកំពុងតែសំដែងនូវលម្អដ៏ក្រណាលមហាគង្គានិង
ព្រួដ៏តណ្ណាលអាកាសវេហាស៍ ហាក់បីដូចជាពួកទេវតានាំគ្នា
ដើរលេងកងសួនទេវាលោក ។

ដំនោរខែកត្តិក ក៏បានបក់មកអំពីទិសខាងដើមយ៉ាង
រំភើយៗ កម្មាត់អស់ពាំងសេចក្តីសុះសាប់ បង្គតអស់ពាំងញើស
ហើយបបោសអង្គែលហាទយវត្តនៃមហាជនឲ្យអស់ នូវ
សេចក្តីខ្នុកខ្នែរយ៉ាងគ្រប់យ៉ាង ដែលមានមកពីថ្ងៃមុន ។
ដល់ពាក់តណ្ណាលអធ្រាត្រ សំឡេងសកវាទំនៅព្រះ
ដំណាក់ផែ ក៏បានបន្លឺឡើងដោយបទយ៉ាងសែនពីរោះ ហាក់
បីដូចជាទឹកអម្រឹត ដែលទេពតាយកមកស្រោចស្រប់បេះដូងនៃ

មហាជនច្រើនកុះករ ត្រជាក់ត្រជុំក្សេមក្សាន្ត សម្បូរ
សម្រន្តក្នុងអារម្មណ៍ដ៏សែនមនោរម្យឥតឧបមា ។
មហាជនសរសើរស្ទើរតែពាល់មាត់ ដល់ពាជរដ្ឋាភិបាល
សង្ឃ ដែលបានខិតខំរៀបចំទីក្រុងភ្នំពេញ ដោយមានវាចា
ថា ពាជនីយើង បើសម្តេចព្រះបិតាទ្រង់គង់នៅជាព្រះអគ្គ-
មគ្គុទេសក៍ជាពហុណា ជាកថានាះនឹងបានទៅជាទីក្រុងមួយយ៉ាង
ល្អឆើតឆាយ ។

សំណួរ

๑. ចូរពន្យល់ពាក្យ ទេសចរ, ប្រទីបផ្កាលា, ឮដីកណ្តាលអាកាស, ហាទយវត្ត, ទឹក-
ត្រី, អម្រឹត, សែនមនោរម, អគ្គមគ្គុទេសក៍ ។

๒– ចូរបង្ហាញន័យនៃពាក្យ "មហា" និងពាក្យ
"ឧត្តម" តើឧស្សគាយ៉ាងណា ? ឧទា-
ហរណ៍ ។

๓– ចូរសង្ខេបន័យពាក្យត្រង់ឃ្លា : "មហាជនប្រុស

ស្រីតុបតែងខ្លួនយ៉ាងល្អគ្រប់ៗគ្នា ឈរនិង
ដើរវេក" ។

មធ្យមសិក្សាប័ត្រ
លើកទី ៣ ថ្ងៃ ៩-៣-៤២(១)

កំណត់ចំណាំ

១- អក្ខរាវិរុទ្ធ -

- ឆេសចរ (ជាទាម. *គឺជនអ្នកធ្វើដំណើរលំហែ*
កម្សាន្ត) ។ *កុំច្រឡំនឹង* ទ្វេសបរណ៌ *ជា*
នាម ប្រែថា ការធ្វើដំណើរកម្សាន្ត ឬឈ្មោះ
ក្រសួង ។ *ក្រសួង* ទ្វេសបរណ៌ ។

- អឹកឆឹក (*សរសេរនឹងស្រៈ ឹ* ។ *ឬអាចសរសេរ*
អ៊ឹកអ៊ឹក ក៏បាន) ។

- សតឥត្ថ (*អាចសរសេរ សតវិត្ថ្រ ដូច្នេះបាន*)។

---

(១) បានដាមានលើកទី ៣ ពីព្រោះលើកទី ៤ ត្រូវធាលោលដោយ"មាន
ឧបសគ្គមិនល្អ ភាលពេលប្រឡងលើកទី ២ នោះ ។

- ប្រែធីប (សរសេរទឹងស្រៈ ី និង ប ។

- លង្ហ (សរសេរតម្រួត មកពីពាក្យ ល្អ ។ ពីមុន

សរសេរ លំអ្ហ បាន) ។

- វេហាស៍ (អាចសរសេរ វ៉ៃហ ដូច្នេះបាន) ។

- ដំណោរ (សរសេរ ន ចុង) ។

- កត្តិក (សរសេរ ត ដើង ត ទឹងស្រៈ ិ និង ក)។

